D99/3/18

**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

| | |
|---|---|
| សំណុំរឿងលេខ: | ០០១/១៨-០៧-២០០៧-អ.វ.ត.ក-ក.ស.ច.ស(អ.ប.ជ០២) |
| ដាក់ទៅ: | អង្គបុរេជំនុំជម្រះ |
| ថ្ងៃដាក់: | ថ្ងៃទី ៣ ខែ តុលា ឆ្នាំ ២០០៨ |
| ភាគីអ្នកដាក់: | សហមេធាវីរបស់លោក អៀង សារី |
| ភាសាដើម: | អង់គ្លេស |
| ប្រភេទឯកសារ: | សាធារណៈ: |

ឯកសារដើម
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 03 / Oct / 2008
ម៉ោង (Time/Heure): 15:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

---

**ពាក្យសុំរបស់លោក អៀង សារី សុំដកគុណវុឌ្ឍិសាស្ត្រាចារ្យ កាសេស៊ី (Cassese) និង សមាជិកមួយចំនួននៃក្រុមប្រឹក្សានិពន្ធ និង គណៈកម្មាធិការនិពន្ធ និងនៃទិនានុប្បវត្តិតុលាការព្រហ្មទណ្ឌអន្តរជាតិ ពីការដាក់សារណាជាលាយលក្ខណ៍អក្សររបស់ *អ្នកដែលមិនមែនជាភាគីនៃរឿងក្តី* ស្តីពីបញ្ហាសហការបទឧក្រិដ្ឋកម្មរួម នៅក្នុងបណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញាប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះករណីរបស់ កាំង ហ្គេកអ៊ាវ ហៅ "ឌុច"**

---

<u>**អ្នកដាក់ឯកសារ៖**</u>

**សហមេធាវីរបស់លោក អៀង សារី**

លោក អាង ឧត្តម

លោក Michael G. KARNAVAS

<u>**អ្នកទទួលឯកសារ៖**</u>

**អង្គបុរេជំនុំជម្រះ**

ចៅក្រម ប្រាក់ គឹមសាន

ចៅក្រម ន័យ ធុល

ចៅក្រម ហួត វុទ្ធី

ចៅក្រម Katinka LAHUIS

ចៅក្រម Rowan DOWNING

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Robert PETIT

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 06 / 10 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: UCH ARUN

តាមរយៈសហមេធាវីរបស់គាត់ (ហៅថា "មេធាវីការពារក្តី") លោក **អៀង សារី** តទៅនេះ ដោយសូមធ្វើការដាក់ពាក្យអនុលោកតាមវិធានផ្ទៃក្នុង ៣៣ ស្នើឱ្យដកហូតគុណវុឌ្ឍិ ពីសាស្ត្រាចារ្យ Antonio Cassese និងសមាជិកគណៈកម្មាធិការនិពន្ធនាយក ព្រមទាំងគណៈកម្មាធិការនិពន្ធនាយក នៃព្រឹត្តិប័ត្រព័ត៌មាននៃយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ ពីការដាក់ជូនសារណាជាលាយលក្ខអក្សររបស់ *អ្នកដែលមិនមែនជាភាគីនៃរឿងក្តី*ចំពោះបញ្ហាសហកម្មឧក្រិដ្ឋកម្មរួម (ហៅថា"JCE") នៅក្នុងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជំទាស់ទៅនឹងដីការបញ្ជូនរឿងទៅជំនុំជម្រះលើករណីរបស់ កាំង ហ្គេកអ៊ាវ ហៅ "ឌុច"[1]។ ពាក្យស្នើសុំនេះត្រូវបានធ្វើឡើងជាការចាំបាច់ ដោយហេតុថា ទាំងស្ត្រាចារ្យ Cassese ឬ ទាំងសមាជិកជាក់លាក់ណាម្នាក់នៃគណៈកម្មាធិការនិពន្ធនាយក ព្រមទាំងគណៈកម្មាធិការនិពន្ធនាយក (ហៅថា"សមាជិកនិពន្ធនាយកជាក់លាក់") នៃព្រឹត្តិប័ត្រព័ត៌មាននៃយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ (ហៅថា "ព្រឹត្តិប័ត្រព័ត៌មាន ឬ ទិនានុប្បវត្តិ") មិនមានលក្ខណៈសម្បត្តិជា*អ្នកដែលមិនមែនជាភាគីនៃរឿងក្តីនោះទេ* ដោយសារតែ ការខ្វះខាតអនាគតិរបស់ពួកគេទៅលើបញ្ហាសហកម្មឧក្រិដ្ឋកម្មរួម ។ <u>ជាពិសេស ដោយសារតែ សាស្ត្រាចារ្យ Cassese មានទំនាស់ផលប្រយោជន៍ក្នុងតួនាទីរបស់គាត់កាលពីពេលមុន ក្នុងនាមជាចៅក្រមមួយរូបនៅក្នុងអង្គជំនុំជម្រះតុលាការកំពូល នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី ដែលទទួលខុសត្រូវចំពោះការបង្កើតនូវអ្វីដែលហៅថាយុត្តិសាស្ត្រ</u>សហកម្មឧក្រិដ្ឋកម្មរួម [2]។ ទាំងស្ត្រាចារ្យ Cassese ទាំងសមាជិកនិពន្ធនាយកជាក់លាក់ណាម្នាក់ក្តីមិនគួរត្រូវបានអនុញ្ញាតិឱ្យធ្វើសេចក្តីព្រាង ត្រួតពិនិត្យ ឬចូលរួមបរិច្ឆាគតាមមធ្យាបានណាមួយចំពោះ សារណាជាលាយលក្ខអក្សរដាក់

---

[1] ពាក្យស្នើសុំរបស់ **អៀង សារី** ឱ្យដកហូតសិទ្ធិពីសាស្ត្រាចារ្យ Antonio Cassese និងសមាជិកគណៈកម្មាធិការនិពន្ធនាយក ព្រមទាំងគណៈកម្មាធិការនិពន្ធនាយកនៃព្រឹត្តិប័ត្រព័ត៌មាន(តទៅនេះហៅថា "ទិនានុប្បវត្តិ ឬព្រឹត្តិប័ត្រ")យុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ ពីការដាក់ជូនសារណាជាលាយលក្ខអក្សររបស់*អ្នកដែលមិនមែនជាភាគីនៃរឿងក្តី* ចំពោះបញ្ហាសហកម្មឧក្រិដ្ឋកម្មរួម ("JCE") នៅក្នុងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជំទាស់ទៅនឹងដីកា បញ្ជូនរឿងទៅជំនុំជម្រះលើករណីរបស់ កាំង ហ្គេកអ៊ាវ ហៅ "ឌុច"។

[2] ក្នុងខណៈពេលដែលអាចឱ្យយល់បានថា ពុំមានចៅក្រមណាមួយរូបនៃអង្គបុរេជំនុំជម្រះបានដឹងពីតួនាទីបច្ចុប្បន្ន និងអតីត របស់សាស្ត្រាចារ្យ Cassese នៅក្នុងការចេញបញ្ហា ការប្រគួតប្រជែង ការលើកស្ទួយ និងការការពារចុះពោះ សហកម្មឧក្រិដ្ឋកម្មរួមថាជាទម្រង់មួយនៃការទទួលខុសត្រូវខាងព្រហ្មទណ្ឌ នោះមន្ត្រីជាន់ខ្ពស់ផ្នែកច្បាប់នៃអង្គបុរេជំនុំជម្រះ ដែលធ្លាប់បានជ្រើសរើសឱ្យបំពេញតួនាទីជាមន្ត្រីច្បាប់នៅក្នុងអង្គជំនុំជម្រះនៃ ICTY ដែលទទួលបានការចាត់តាំងឱ្យជួយដល់ចៅក្រមមួយរូបដែលបានបដិសេធមិនអនុវត្តសហកម្មឧក្រិដ្ឋកម្មរួមទេ តែបែរជាជ្រើសរើសអនុវត្តការសមគំនិតសហចារីថាជាទម្រង់មួយនៃការទទួលខុសត្រូវជំនួសទៅវិញនោះ ពិតជាបានដឹងដោយមិនអាចប្រកែកបានទេ មុនពេលជ្រើសរើសរូបគាត់ឱ្យដាក់សារណាក្នុងនាមជា*អ្នកដែលមិនមែនជាភាគីនៃរឿងក្តី*នោះ ។

ជូនទៅអង្គបុរេជំនុំជំរះនោះទេ។ លើសពីនេះទៅទៀត ទាំងសាស្ត្រាចារ្យ Cassese ទាំងសមាជិកនិពន្ធនាយកផ្សេងទៀត មិនគួរចូលរួមពាក់ព័ន្ធនៅក្នុងការជ្រើសរើសសមាជិកដទៃទៀតនៃព្រឹត្តិប័ត្រព័ត៌មាន ដែលមានពិតជាមានលក្ខណៈសម្បត្តិធ្វើជា*អ្នកដែលមិនមែនជាភាគីនៃរឿងក្តី* ហើយដែលមិនប្រឈមមុខទៅនឹងទំនាស់ផលប្រយោជន៍។ ដូចដែលបានជំទាស់តវ៉ានៅក្នុងនេះរួចមកហើយ ការអនុញ្ញាតឱ្យសាស្ត្រាចារ្យ Cassese និងអ្នកដទៃទៀត ដែលជាអ្នកនិពន្ធ អ្នកការពារ និងជាអ្នកលើកស្ទួយដល់សហកម្មឧក្រិដ្ឋកម្មរួមជាចំបង (ក៏ដូចជា អ្នកផ្សេងទៀតដែលបានចូលរួមពាក់ព័ន្ធក្នុងបញ្ហាសហកម្មឧក្រិដ្ឋកម្មរួម ដោយផ្ទាល់ ឬដោយប្រយោល pro or con) ដើរតួជា*អ្នកដែលមិនមែនជាភាគីនៃរឿងក្តី* នឹងមិនជានាអ្វីបានក្រៅតែពី result-determinative submission។ ហេតុដូច្នេះ ការឱ្យសាស្ត្រាចារ្យ Cassese ឬសមាជិកនិពន្ធនាយកផ្សេងទៀតចូលករួមធ្វើជា*អ្នកដែលមិនមែនជាភាគីនៃរឿងក្តី* នៅចំពោះមុខ អ.វ.ត.ក ពិតជាមិនត្រឹមត្រូវ និងអយុត្តិធម៌យ៉ាងខ្លាំង ដែលជាការនាំឱ្យអន្តរាយ និងនាំឱ្យអាប់ឱនដល់កិត្តិយសនៃប្រព័ន្ធយុត្តិធម៌ ប្រទេសកម្ពុជា ជាពិសេស គឺ អ.វ.ត.ក នេះតែម្តង។

## I. សេចក្តីផ្តើម

1. ក.ស.ព បានប្តឹងឧទ្ធរណ៍ជំទាស់ទៅនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលចេញដោយ ក.ស.ច.ស កាលពីថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០០៨[3]។

2. មេធាវីការពាររបស់ **អៀង សារី** បានដាក់សំណើរមួយដើម្បីស្នើសុំឱ្យអនុវត្តសហកម្មឧក្រិដ្ឋកម្មរួមនៅ អ.វ.ត.ក ដែលជាការឆ្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់ ក.ស.ព[4]។ ជំនួយឱ្យការមានហេតុផលដ៏ខ្លាំងក្លាបំផុតថាតើហេតុអ្វីបានជាលោក **អៀង សារី** ជាភាគីមួយមានប្រយោជន៍ចំពោះ បញ្ហា

---

[3] ករណីរបស់ កាំង ហ្គេកអ៊ាវ ហៅ "ឌុច" ០០១/១៨-០៧-២០០៧-អ.វ.ត.ក-ក.ស.ច.ស(អ.ប.ជ០២)។ បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជំទាស់ទៅនឹងដីការបញ្ជូនរឿងទៅជំនុំជម្រះលើករណីរបស់ កាំង ហ្គេកអ៊ាវ ហៅ "ឌុច" ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០០៨។

[4] ករណីរបស់ កាំង ហ្គេកអ៊ាវ ហៅ "ឌុច" ០០១/១៨-០៧-២០០៧-អ.វ.ត.ក-ក.ស.ច.ស (អ.ប.ជ០២)។ សំណើជាបន្ទាន់របស់លោក **អៀង សារី** សុំដាក់អំណះអំណាងស្តីអំពីការអនុវត្តនូវការទទួលខុសត្រូវជាទម្រង់សហកម្មឧក្រិដ្ឋកម្មរួម នៅក្នុងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជំទាស់ទៅនឹងដីការបញ្ជូនរឿងទៅជំនុំជម្រះលើករណីរបស់ កាំង ហ្គេកអ៊ាវ ហៅ "ឌុច" ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ (ហៅថា "សំណើ") ។

សហកម្មឧក្រិដ្ឋកម្មរួម ហើយការដកចេញការចូលរួមរបស់គាត់ គឺបណ្ដាលឱ្យមានអតុល្យ ភាពខាងនីតិវិធី និងភាពអយុត្តិធម៌ ដែលអង្គបុរេជំនុំជម្រះមិនទាន់បានចេញសេចក្ដីសម្រេចនៅឡើយទេ។

3. ក្រោយពីការដាក់សំណើនេះ អង្គបុរេជំនុំជម្រះបានអញ្ជើញសាស្ត្រាចារ្យ Antonio Cassese រួមទាំងសមាជិកគណៈកម្មាធិការនិពន្ធនាយក និងគណៈកម្មាធិការនិពន្ធនាយកនៃព្រឹត្តិប័ត្រព័ត៌មាននេះឱ្យដាក់សារណាជាលាយលក្ខអក្សរក្នុងនាម*អ្នកដែលមិនមែនជាភាគីនៃរឿងក្ដី* ទៅលើបញ្ហាដូចមានខាងក្រោម:[5]

(១) ការអភិវឌ្ឍន៍នៃទ្រឹស្ដីសហកម្មឧក្រិដ្ឋកម្មរួម និងការវិវត្តន៍នៃទ្រឹស្ដីលើទម្រង់នៃការទទួលខុសត្រូវនេះ ដោយមានការសំអាងពិសេសទៅនឹងអំឡុងពេលចន្លោះពីឆ្នាំ ១៩៧៥ ដល់ ១៩៧៩ និង

(២)ថាតើសហកម្មឧក្រិដ្ឋកម្មរួមគឺជាទម្រង់មួយនៃការទទួលខុសត្រូវដែលអាចយកមកអនុវត្តនៅចំពោះមុខ អ.វ.ត.ក បានដែរឬយ៉ាង ដោយការពិចារណាទៅលើអង្គហេតុដែលថាឧក្រិដ្ឋកម្មទាំងនេះត្រូវបានប្រព្រឹត្តឡើងនៅអំឡុងពេលចន្លោះពីឆ្នាំ ១៩៧៥ ដល់ ១៩៧៩។

4. លិខិតអញ្ជើញនេះត្រូវបានពន្យាពេលដល់ថ្ងៃទី១ តុលា ២០០៨ ផ្ញើទៅមជ្ឈមណ្ឌលសិទ្ធិមនុស្ស និងសាកលវិទ្យាល័យពហុនីតិម៉ាកហ្គីល (Legal Pluralism of McGill University) លោកបណ្ឌិតសាស្ត្រាចារ្យ jur. Kai Ambos នៃសាកលវិទ្យាល័យ the Georg August នៃ of Gottingen (the Georg August University of Gottingen)[6]។

## II. សេចក្ដីសង្ខេបនូវទឡ្ហីករណ៍

5. តួនាទីរបស់*អ្នកដែលមិនមែនជាភាគីនៃរឿងក្ដី* គឺជាតួនាទីមួយដែលឯករាជ្យ និងអនាគតិ។ ការប្រើប្រាស់តួនាទីនេះគឺមិនមែននិយាយឡើងវិញពីអ្វីដែល អ.វ.ត.ក មានរួចទោះហើយនោះទេ ប៉ុន្តែដើម្បីចូលរួមពាក់ព័ន្ធនៅក្នុងភាពមិនលំអៀង ហ្មត់ចត់ ព្រមទាំងការពិនិត្យ និងការវិភាគឡើងវិញប្រកបដោយតុល្យភាពនូវចំនុចជាក់ស្ដែងមួយចំនួនដែលជាការព្រួយបារម្ភចំពោះបញ្ហានេះ។ ដោយ

---

[5] ករណីរបស់ កាំង ហ្គេកអ៊ាវ ហៅ "ឌុច" ០០១/១៨-០៧-២០០៧-អ.វ.ត.ក-ក.ស.ច.ស (អ.ប.ជ ០២)។ លិខិតអញ្ជើញអ្នកដែលមិនមែនជាភាគីនៃរឿងក្ដី ចុះថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ២០០៨ ("លិខិតអញ្ជើញ") ទំព័រទី១ ។

[6] ការបញ្ជាក់បន្ថែមនៃលិខិតអញ្ជើញលើកទីពីរ។ *Case of Kaing Guek Eav "Duch"*, 001/18-07-2007-ECCC-OCIJ (PTC02) D/99/3/13, Invitation to Amicus Curiae, 25 September 2008, *Case of Kaing Guek Eav "Duch"*, 001/18-07-2007-ECCC-OCIJ (PTC02) D/99/3/14, Invitation to Amicus Curiae, 25 September 2008.

សារតែចំណងទាក់ទងជាក់ស្តែង និងលេចញធ្លោរវាងសហកម្មឧក្រិដ្ឋកម្មរួម និងសាស្ត្រាចារ្យ Cassese ព្រមទាំងសមាជិកនិពន្ធនាយកផ្សេងទៀត នោះអ្នកទាំងនេះមិនអាចសរសេរដោយលំអៀងចំពោះបញ្ហាដែលអង្គបុរេជំនុំជម្រះបានលើកឡើងរួមមកហើយនោះទេ។ ហេតុដូច្នេះ ពួកគាត់មិនមានលក្ខណៈសម្បត្តិដើម្បីដើរតួជា*អ្នកដែលមិនមែនជាភាគីនៃរឿងក្តី* នៅក្នុងករណីនេះបានទេ។

6. សាស្ត្រាចារ្យ Cassese ព្រមទាំងសមាជិកនិពន្ធនាយកផ្សេងទៀតត្រូវ បានស្នើ សុំឱ្យសរសេរសារណាជាលាយលក្ខអក្សររបស់ខ្លួននៅក្នុងសមត្ថភាពតុលាការ ជាជាង*អ្នកដែលមិនមែនជាភាគីនៃរឿងក្តី*។ បើដូច្នោះទេ ពួកគាត់ត្រូវតែអនុវត្តតាមក្រមវិជ្ជាជីវៈតុលាការរបស់ អ.វ.ត.ក ជាពិសេសភារកិច្ចនៃឯករាជ្យភាព និងអនាគតិ។ ប្រសិនបើ សាស្ត្រាចារ្យ Cassese ព្រមទាំងសមាជិកនិពន្ធនាយកផ្សេងទៀតព្រមទទួលយកលិខិតអញ្ជើញនេះ នោះពួកគាត់ត្រូវកំពុងតែរំលោភលើក្រមនេះ ដែលចំនុចណាមួយក៏ដោយ គឺត្រូវមានភាពមិនលំអៀងមកលើប្រធានបទនេះ។ លើសពីនេះទៅទៀត សាស្ត្រាចារ្យ Cassese គឺជាផ្នែកមួយនៃអង្គជំនុំជម្រះតុលាការកំពូលលើរឿងក្តី *Tadić* ដែលបង្កើតបានសហកម្មឧក្រិដ្ឋកម្មរួម[7] ហើយការអនុញ្ញាតឱ្យរូបគាត់ដោះស្រាយជាចំបងទៅលើសំណួរដដែលជាថ្មីម្តងទៀតនៅចំពោះមុខ អ.វ.ត.ក គឺប្រៀបបាននឹងឱ្យចៅក្រមសាលាដំបូងម្នាក់ទៅអង្គុយកាត់ក្តីលើបណ្តឹងឧទ្ធរណ៍នៃរឿងដដែលដូច្នោះដែរ។

7. ដើម្បីកែប្រែស្ថានភាពខាងលើ អង្គបុរេជំនុំត្រូវ: ១) ដកហូតលិខិតអញ្ជើញមកវិញ ២) បដិសេធមិនទទួលសារណាជាលាយលក្ខអក្សរទាំងឡាយចំពោះបញ្ហានេះ ដែលបានដាក់ជូនដោយការចូលរួមពីសាស្ត្រាចារ្យ Cassese ព្រមទាំងសមាជិកនិពន្ធនាយកផ្សេងទៀត និង ៣) ហាមឃាត់សាស្ត្រាចារ្យ Cassese ព្រមទាំងសមាជិកនិពន្ធនាយកផ្សេងទៀតពីការជ្រើសរើសសមាជិកដទៃទៀតដែលនឹងត្រូវសរសេរសារណាដែលបានស្នើសុំនេះ ឬ ៤) ផ្តល់លិខិតអញ្ជើញនេះទៅឱ្យសមាគមក្រុមមេធាវីការពារក្តី ដែលកំពុងការពារក្តីនៅចំពោះមុខតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី (ហៅថា "ADC-ICTY") ឱ្យដាក់ជូនសារណាទៅលើបញ្ហាទាំងនេះ។

---

[7] រឿងក្តីរវាងរដ្ឋអាជ្ញា តទល់នឹង *Tadić*, IT-94-1-A, សាដីកា ចុះថ្ងៃទី១៥ កក្កដា ១៩៩៩ (ហៅថា "សាលដីកា *Tadić*") ពីកថាខណ្ឌ ១៨៥ ដល់ ២៣៤ ។

## III. អង្គច្បាប់

### ក. តួនាទីរបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី

8. វិធានផ្ទៃក្នុង ៣៣ ចែងដូចខាងក្រោម:

១. នៅគ្រប់ដំណាក់កាលនៃដំណើរការនីតិវិធី បើយល់ថាចាំបាច់ដើម្បីវិនិច្ឆ័យទោសឲ្យបានត្រឹមត្រូវ សហចៅក្រមស៊ើបអង្កេត ឬ អង្គបុរេជំនុំជម្រះអាចអញ្ជើញ ឬ ផ្តល់ឱកាសឲ្យអង្គការ ឬ បុគ្គលណាមួយផ្តល់ជូននូវសារណាជាលាយលក្ខអក្សរ ពាក់ព័ន្ធទៅនឹងបញ្ហាណាមួយក៏បាន ក្នុងនាមជាអ្នកឯកទេសអមតុលាការ។ សហចៅក្រមស៊ើបអង្កេត ឬ អង្គបុរេជំនុំជម្រះដែលពាក់ព័ន្ធត្រូវកំណត់ពេលវេលាឲ្យដាក់សារណានេះ ប្រសិនបើត្រូវធ្វើ។

២. សារណាដែលធ្វើឡើងនៅក្រោមវិធាននេះ ត្រូវប្រគល់ទៅឲ្យក្រឡាបញ្ជីរបស់សហចៅក្រមស៊ើបអង្កេត ឬ អង្គបុរេជំនុំជម្រះដែលពាក់ព័ន្ធ។ ក្រឡាបញ្ជីត្រូវប្រគល់ឯកសារចម្លងមួយច្បាប់ទៅឲ្យសហព្រះរាជអាជ្ញា និង មេធាវីរបស់ភាគីដទៃទៀត ដើម្បីមានឱកាសឆ្លើយតប[8]។

9. ទាំងវិធានផ្ទៃក្នុង និងច្បាប់កម្ពុជាមិនបានផ្តល់ការណែនាំថាតើតួនាទីរបស់*អ្នកដែលមិនមែនជាភាគីនៃរឿងក្តី*ចាំបាច់ប៉ុណ្ណានោះទេ។ ប៉ុន្តែ តុលាការអន្តរជាតិភាគច្រើនទទួលយកសារណារបស់*អ្នកដែលមិនមែនជាភាគីនៃរឿងក្តី*ដើម្បីជួយដល់ខ្លួនទៅលើបញ្ហាច្បាប់ពិសេសៗ។ តុលាការយុត្តិធម៌អន្តរជាតិអនុញ្ញាតឲ្យ*អ្នកដែលមិនមែនជាភាគីនៃរឿងក្តី* ទាំងក្នុងនីតិវិធីដោះស្រាយវិវាទ និងនីតិវិធីផ្តល់ប្រឹក្សា ប៉ុន្តែ មានវិធានតឹងរ៉ឹងសមហេតុផលចំពោះវិធីដោះស្រាយវិវាទ ដោយអនុញ្ញាតឲ្យតែអង្គការនៃរដ្ឋពាក់ព័ន្ធចូលរួមប៉ុណ្ណោះ[9]។ តុលាការសិទ្ធិមនុស្សអឺរ៉ុបទទួលយកសារណារបស់*អ្នកដែលមិនមែនជាភាគីនៃរឿងក្តី* "ដើម្បីផលប្រយោជន៍នៃការចាត់ចែងយុត្តិធម៌ឲ្យបានត្រឹមត្រូវ" ចំពោះជន

---

[8] វិសោធនកម្មលើកទី ២ ចុះថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០០៨ ។

[9] មាត្រា ៣៤(២) នៃលក្ខន្តិកៈតុលាការយុត្តិធម៌អន្តរជាតិ ចែងថា "ដោយយោងទៅលើ និងស្របតាមវិធានរបស់ខ្លួន តុលាការអាចស្នើសុំព័ត៌មានពីអង្គការអន្តរជាតិសាធារណៈនូវព័ត៌មានដែលពាក់ព័ន្ធនឹងរឿងក្តីនៅចំពោះខ្លួន និងត្រូវទទួលព័ត៌មានដែលបានផ្តល់មកជូនដោយអង្គការទាំងនោះ តាមគំនិតផ្តួចផ្តើមរបស់គេ"។ វិធាន ៦៩(៤) ហាមឃាត់អង្គការទាំងនោះចំពោះរដ្ឋដូច្នេះ អង្គការក្រៅរដ្ឋាភិបាលមិនមានឱកាសនៅក្នុងដំណើរការនីតិវិធីដោះស្រាយវិវាទនោះទេ។ ប៉ុន្តែ ទាក់ទងទៅនឹងការផ្តល់យោបល់ជាប្រឹក្សា មាត្រា ៦៦(៤) ចែងថា រដ្ឋ ឬ "អង្គការអន្តរជាតិទាំងឡាយ" អាចមានឱកាស ប្រសិនបើតុលាការយល់ ព្រម ឬ ស្នើសុំ។ ចំនុចនេះរួមមានទាំងអង្គការអន្តរជាតិសាធារណៈ ឬ ឯកជន ដោយរាប់បញ្ចូលទាំងអង្គការក្រៅរដ្ឋាភិបាល (សេចក្តីណែនាំអនុវត្ត XII)។ ព័ត៌មានបែបនោះអាចផ្តល់ជូនក្នុងទម្រង់ជាលាយលក្ខអក្សរ ឬ ដោយផ្ទាល់មាត់ក៏បាន ឲ្យតែព័ត៌មាននោះពាក់ព័ន្ធទៅនឹងសំណួរដែលមាននៅក្នុងដៃ។

ទាំងឡាយដែលពាក់ព័ន្ធ ជាជាងអ្នកដាក់សារណា[10]។ ប្រហាក់ប្រហែលគ្នានេះដែរ តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា(ICTR)[11] តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី(ICTY)[12] តុលាការឧក្រិដ្ឋកម្មអន្តរជាតិ(ICC)[13] និងតុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន (SCSL)[14] បានអនុញ្ញាត *អ្នកដែលមិនមែនជាភាគីនៃរឿងក្តី* ឲ្យដាក់សារណាជូនបាន។

**ខ. *លក្ខខណ្ឌតម្រូវឲ្យអ្នកដែលមិនមែនជាភាគីនៃរឿងក្តី* មានឯករាជ្យភាព និង អនាគតិ**

10. ពាក្យថា *អ្នកដែលមិនមែនជាភាគីនៃរឿងក្តី* (*amicus curiae*) មានន័យថា "មិត្តរបស់តុលាការ"។ ពាក្យនេះអនុវត្តចំពោះអ្នកដែលនៅជិតកន្លែងដែលព្រឹត្តិការណ៍កើតមានឡើង *"ដែលមិនមានផលប្រយោជន៍ផលប្រយោជន៍នៅក្នុងមូលហេតុនេះ* ដែលតាមការដឹងរបស់ខ្លួនស្នើសុំទៅលើចំនុចណាមួយនៃអង្គហេតុ ឬ អង្គច្បាប់ សម្រាប់ព័ត៌មានរបស់ចៅក្រមកាត់សេចក្តី"[15]។

11. *អ្នកដែលមិនមែនជាភាគីនៃរឿងក្តីទាំងឡាយ* ដែលចូលខ្លួននៅចំពោះមុខតុលាការព្រហ្មទណ្ឌ ដែលយកច្បាប់ព្រហ្មទណ្ឌអន្តរជាតិមកអនុវត្ត គួរតែមានឯករាជ្យភាព និង អនាគតិ[16]។ ឯករាជ្យភាព

---

[10] វិធានទី ៣៧(២) នៃវិធានស្តីពីនីតិវិធីរបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប។

[11] វិធានទី៧៤ នៃវិធានស្តីពីនីតិវិធី និង ភស្តុតាង របស់ ICTR ។

[12] វិធានទី៧៤ នៃវិធានស្តីពីនីតិវិធី និង ភស្តុតាង របស់ ICTY (ហៅថា "ICTY RPE") ។ នៅ ICTY *អ្នកដែលមិនមែនជាភាគីនៃរឿងក្តី* ទាំងអស់ត្រូវបានតម្រូវឲ្យធ្វើកំណត់ហេតុ "បញ្ជាក់ និង ពន្យល់ពីការប្រាស្រ័យទាក់ទង ឬ ទំនាក់ទំនងទាំងឡាយដែល អ្នកដាក់សារណាធ្លាប់មាន ឬ កំពុងមានជាមួយភាគីនៃរឿងក្តី" នៅក្រោមកថាខណ្ឌ ៣(គ) នៃសេចក្តីណែនាំអនុវត្តទៅលើ *ព័ត៌មានស្តីពីការដាក់សារណាដោយអ្នកដែលមិនមែនជាភាគីនៃរឿងក្តី*, IT/122, ចុះថ្ងៃទី ២៧ មីនា ១៩៩៧ កថាខណ្ឌ ៣(ច) ("ICTY Information")។

[13] វិធានទី១០៣ នៃវិធានស្តីពីនីតិវិធី និង ភស្តុតាង របស់ ICC ។

[14] វិធានទី៧៤ នៃវិធានស្តីពីនីតិវិធី និង ភស្តុតាង របស់ SCSL ។ *សូមមើលផងដែរ* នូវសេចក្តីណែនាំអនុវត្តស្តីពីការដាក់សារណាដោយ*អ្នកដែលមិនមែនជាភាគីនៃរឿងក្តី* ស្របតាមវិធានទី៧៤ នៃវិធានស្តីពីនីតិវិធី និង ភស្តុតាង របស់តុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន ចុះថ្ងៃទី២០ តុលា ឆ្នាំ២០០៤។ វាស្ទើរតែដូចគ្នាទៅនឹងសេចក្តីណែនាំអនុវត្តរបស់ CTY រួមទាំង សិទ្ធិរបស់ ICTY ក្នុងការដាក់លក្ខខណ្ឌ ឬ ការដាក់កម្រិតទៅលើ*អ្នកដែលមិនមែនជាភាគីនៃរឿងក្តី* ដែលតុលាការយល់ថាចាំបាច់។

[15] វចនានុក្រម Abbott ស្តីពី ពាក្យ និង ឃ្លា ដែលបានប្រើនៅក្នុងយុត្តិសាស្ត្រអង់គ្លេស ឬ អាមេរិកកាំង ។ Abbott's Dictionary of Terms and Phrases Used in American or English Jurisprudence (Little, Brown & Co, Boston 1879) (បន្ថែមសេចក្តីបញ្ជាក់).

[16] សូមមើល Sarah Williams និង Hannah Woolaver ។ *តួនាទីរបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តីនៅចំពោះមុខតុលាការឧក្រិដ្ឋកម្មអន្តរជាតិ* ៦ INT'L CRIM. L REV 151-89 (2006)។

00225611



មានន័យថា *អ្នកដែលមិនមែនជាភាគីនៃរឿងក្តី* មិនត្រូវទទួលឥទ្ធិពលពីខាងក្រៅនោះឡើយ នៅពេលដែលខ្លួនធ្វើសេចក្តីសម្រេចចិត្ត។ អនាគិត អាចឲ្យន័យថា *អ្នកដែលមិនមែនជាភាគីនៃរឿងក្តី* ធ្វើសកម្មភាពនៅក្នុងលក្ខណៈដែលត្រឹមត្រូវ និង យុត្តិធម៌ ដោយមិនផ្តល់ប្រយោជន៍ឲ្យភាគីម្ខាងជាងភាគីម្ខាងទៀត និងមិនត្រូវមានភាពលំអៀងនោះឡើយ។ ភាពលំអៀងបែបនេះអាចជាការពិត ឬ ជា perceived[17]។ ឯករាជ្យភាព និង អនាគតិ ត្រូវបានគេពិចារណាថាជាផ្នែកមួយនៃសិទ្ធិទទួលបានការកាត់សេចក្តីមួយប្រកបដោយយុត្តិធម៌ ដែលមានចែងនៅក្នុងមាត្រា ១៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ[18]។ ដូច្នេះ សារណាទាំងឡាយដែលដាក់ជូនដោយ *អ្នកដែលមិនមែនជាភាគីនៃរឿងក្តី* គួរជួយដល់តុលាការក្នុងការបំពេញបន្ថែមចន្លោះប្រហោងច្បាប់ និងមិនត្រូវប្រើប្រាស់ដូចជា រថយន្តសម្រាប់បម្រើផលប្រយោជន៍របស់ភាគីណាមួយឡើយ។ *អ្នកដែលមិនមែនជាភាគីនៃរឿងក្តី* មិនមែនជាគូបដិបក្ខ ឬជាសម្ព័ន្ធមិត្តរបស់អ្នកណាម្នាក់ឡើយ ប៉ុន្តែ ត្រូវបំពេញការងារដោយអព្យាក្រឹត្យ និងចំទិសដៅ[19]។

12. តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី មិនខ្លាចនឹងដកចេញ *អ្នកដែលមិនមែនជាភាគីនៃរឿងក្តី* នោះទេ ការមន្ទិលសង្ស័យទៅលើអព្យាក្រិដ្ឋភាពរបស់ពួកគេកើតមានឡើងនោះ។ នៅក្នុងរឿងក្តីរបស់ *Milošević* អង្គជំនុំជម្រះសាលាដំបូងបានដកហូតការចាត់តាំងរបស់ *អ្នកដែលមិនមែនជាភាគីនៃរឿងក្តី* មកវិញ ដោយសារថា គេបានបញ្ចេញគំនិតយោបល់ដែលមានលក្ខណៈអវិជ្ជមាន

---

[17] រឿងក្តីរវាង រដ្ឋអាជ្ញា តទល់នឹង *Milošević*, IT-02-54, សេចក្តីសម្រេចទាក់ទងនឹងសារណារបស់ *អ្នកដែលមិនមែនជាភាគីនៃរឿងក្តី* សេចក្តីសម្រេច ចុះថ្ងៃទី១០ តុលា ២០០២ (ហៅថា "សេចក្តីសម្រេច *Milošević*")។ អង្គជំនុំជម្រះសាលាដំបូងបានពិនិត្យមើលកំណត់ហេតុផ្តល់ចម្លើយដែលធ្វើឡើងដោយ *អ្នកដែលមិនមែនជាភាគីនៃរឿងក្តី* ដោយបានសន្និដ្ឋានថា បើពិនិត្យជារួមទៅ កំណត់ហេតុទាំងនេះបង្ហាញនូវ"ភាពដែលអាចឲ្យដឹងបានដោយមានហេតុផលនៃភាពលំអៀង"។

[18] មាត្រា ១៤(១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ ចែងថា "ជនគ្រប់រូបត្រូវមានសិទ្ធិស្មើគ្នានៅចំពោះមុខតុលាការ និងសាលាជម្រះក្តី។ ជនគ្រប់រូបត្រូវមានសិទ្ធិឲ្យ *សាលាជម្រះក្តីមានសមត្ថកិច្ច ឯករាជ្យ និងមិនលំអៀង* ដែលបង្កើតឡើងដោយច្បាប់ ជំនុំជម្រះរឿងក្តីរបស់ខ្លួនដោយសមធម៌ និងជាសាធារណៈ ដើម្បីសម្រេចលើការចោទប្រកាន់មកលើខ្លួនក្នុងវិស័យព្រហ្មទណ្ឌ ឬលើសិទ្ធិ និងករណីយកិច្ច ក្នុងវិស័យរដ្ឋប្បវេណី...។ (មានសេចក្តីបញ្ជាក់បន្ថែម) ។

[19] Jona Razzaque, *ការផ្លាស់ប្តូរតួនាទីរបស់មិត្តរបស់តុលាការនៅក្នុងតុលាការ និងសាលាជម្រះក្តីអន្តរជាតិ* ១ NON STATE ACTORS AND INTERNATIONAL LAW (2002) 169, 171 ។ *សូមមើលផងដែរ* រឿងក្តីរវាង *Vermeulen* តទល់នឹងប្រទេស បែលហ្ស៊ិក (1996) ECHR Application No. 19075/91 ដែលតុលាការសិទ្ធិមនុស្សអឺរ៉ុបក៏បានលើកឡើងផងដែរពីសារៈសំខាន់នៃអព្យាក្រិត្យភាពរបស់ *អ្នកដែលមិនមែនជាភាគីនៃរឿងក្តី* ។

ចំពោះជនជាប់ចោទ។ ក្នុងការដកហូតមកវិញបែបនេះ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា:

"ភាពមិនច្បាស់លាស់នៅក្នុងទស្សនៈរបស់*អ្នកដែលមិនមែនជាភាគីនៃរឿងក្តី* នោះគឺភាពស្មោះត្រង់ដែលតុលាការឆ្លើយចំពោះ"មិត្តតុលាការ"ឱ្យធ្វើសកម្មភាពឱ្យបានត្រឹមត្រូវក្នុងការបំពេញករណីយកិច្ចរបស់ខ្លួន។ ក្នុងកាលៈទេសៈបែបនេះ អង្គជំនុំជម្រះមិនអាចមានទំនុកចិត្តទេថា អ្នកដែលមិនមែនជាភាគីនៃរឿងក្តីនឹងបោះបង់ករណីយកិច្ចរបស់ខ្លួន (ដែលរួមមានទាំង ការនាំឱ្យមានការយកចិត្តទុកដាក់របស់ខ្លួននូវការការពារធ្វើចំពោះជនជាប់ចោទ) ដែលតម្រូវឱ្យមានអព្យាក្រិត្យភាព"[20]។

13. វិធីប្រហាក់ប្រហែលគ្នានេះត្រូវបានតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ្វាន់ដា យកមកអនុវត្ត។ នៅក្នុងរឿងក្តី *Kayishema* អង្គជំនុំជម្រះសាលាដំបូងបានបកស្រាយវិធានទី ៧៤ នៃវិធានស្តីពីនីតិវិធី និង ភស្តុតាងរបស់ខ្លួន (RPE) ដែលអនុញ្ញាតឱ្យអ្នកដែលមិនមែនជាភាគីនៃរឿងក្តីដាក់សារណា ដោយតម្រូវឱ្យ*អ្នកដែលមិនមែនជាភាគីនៃរឿងក្តី*មានអនាគតិ[21]។ អង្គជំនុំជម្រះបានកត់សម្គាល់ឃើញថា: "តួនាទីរបស់*អ្នកដែលមិនមែនជាភាគីនៃរឿងក្តី* គឺមិនមែនដើម្បីការពារផលប្រយោជន៍ណាមួយ ក្រៅតែពីការជួយអង្គជំនុំជម្រះឱ្យសម្រេចរឿងក្តីឱ្យបានត្រឹមត្រូវនោះឡើយ"[22]។ *អ្នកដែលមិនមែនជាភាគីនៃរឿងក្តី* មិនអាចប្រើប្រាស់សិទ្ធិចូលរួមសវនាការរបស់ខ្លួនដើម្បីជំរុញឱ្យមានរបៀបវារៈដាច់ដោយឡែក ជាពិសេស របៀបវារៈរបស់ខ្លួនផ្ទាល់បាននោះឡើយ។

14. ប្រព័ន្ធច្បាប់ជាតិជាច្រើនក៏បានតម្រូវឱ្យអ្នកដែលមិនមែនជាភាគីនៃរឿងក្តីមានឯករាជ្យភាព និងអនាគតិផងដែរ។ នៅចក្រភពអង់គ្លេស និង ប្រទេសខំមីនវែលស៍ មានការសង្កត់ធ្ងន់យ៉ាងខ្លាំងទៅលើឯករាជ្យភាព និងភាពមិនលំអៀង។ តុលាការអង់គ្លេសលើកឡើងដោយសង្កត់ធ្ងន់ថា តួនាទីរបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី គឺដើម្បី"ជួយតុលាការដោយការលើកឡើងពីច្បាប់ប្រកបដោយអនាគតិ"[23]។ បន្ថែមលើនេះទៅទៀត របាយការណ៍ថ្មីៗមួយស្តីពីកំណែទម្រង់នៃវិធានអន្តរាគមន៍នៅក្នុងប្រទេសអង់គ្លេសបាននិយាយថា អ្នកដែលមិនមែនជាភាគីនៃរឿងក្តី "មិនមានផលប្រយោជន៍អ្វីដើម្បីតំណាងតុលាការនោះទេ ហើយគេអាចចូលខ្លួនតែនៅពេលណាមានសំណើពីតុលាការតែ

---

[20] *សូមមើល* សេចក្តីសម្រេច *Milošević* ។

[21] រឿងក្តីរវាង រដ្ឋអាជ្ញា តទល់នឹង *Kayishema,* ICTR-2005-87-I, សេចក្តីសម្រេចទៅលើសំណើឱ្យមានអ្នកដែលមិនមែនជាភាគីនៃរឿងក្តីរបស់មេធាវីការពារក្តីរបស់ Gaspard Kanyarukiga ចុះថ្ងៃទី១៤ កញ្ញា ២០០៧ ។

[22] ដូចគ្នាខាងលើ កថាខណ្ឌ ៦ ។

[23] រឿងក្តីរវាង *Allen* តទល់នឹង *Sir Albert McAlpine & Sons Ltd.* (1968) 2 Q.B. 229, p.266 (មានសេចក្តីបញ្ជាក់បន្ថែម)។

ប៉ុណ្ណោះ"[24]។ នៅក្នុងប្រទេសបារាំង តួនាទីរបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តីមិនបានចែងឲ្យបានច្បាស់លាស់នោះទេ ប៉ុន្តែ មានលក្ខណៈស្រដៀងគ្នាទៅនឹងតួនាទីរបស់ស្នងការរដ្ឋាភិបាល (*Commissaire du Gouvernement*)[25]។ ស្នងការត្រូវតែមានភាពមិនលំអៀង និង "ពន្យល់ពីបញ្ហាដែលនាំឲ្យមានវិវាទ និងដាក់ចេញសេចក្តីសន្និដ្ឋានក្នុងលក្ខណៈមួយដែលមានឯករាជ្យទាំងស្រុង"[26]។

## គ. លក្ខខណ្ឌតម្រូវផ្នែកនីតិវិធី

15. តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី ផ្តល់គោលការណ៍ណែនាំដូចមានខាងក្រោមស្តីពីការដាក់សារណាជាលាយលក្ខអក្សរ[27]។ កថាខណ្ឌ ៥(គ) នៃព័ត៌មានស្តីពីសេចក្តីណែនាំអនុវត្តកំណត់ថា:

(គ) ប្រសិនបើអង្គជំនុំជម្រះកោះហៅ ឬ អញ្ជើញឲ្យអ្នកដែលមិនមែនជាភាគីនៃរឿងក្តីឲ្យដាក់សារណា នោះអង្គជំនុំជម្រះត្រូវផ្តល់ឱកាសឲ្យភាគីនីមួយៗធ្វើការជំទាស់តវ៉ានឹងសារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី ហើយក្នុងករណីខ្លះ ត្រូវរក្សាទុកអំណាចដើម្បីបដិសេធសារណាដែលបានផ្តល់ជូននោះ[28]។

16. ហេតុដូច្នេះ ភាគីនីមួយៗដែលចូលរួមក្នុងដំណើរការនីតិវិធីនៅចំពោះមុខ ICTY មានសិទ្ធិជាស្វ័យប្រវត្តិក្នុងការជំទាស់ទៅនឹងសារណារបស់*អ្នកដែលមិនមែនជាភាគីនៃរឿងក្តី*។ អង្គជំនុំជម្រះដែលធ្វើការសម្រេចសេចក្តីក៏អាចជំទាស់នឹងសារណាជាលាយលក្ខអក្សរជាក់ស្តែងនេះបានដែរ ទោះបីជាខ្លួនបានអញ្ជើញ*អ្នកដែលមិនមែនជាភាគីនៃរឿងក្តី*ដែលល្បីល្បាញក្តី និងឧបមាថា គ្មានភាគីណាមួយជំទាស់ទោះនឹង *អ្នកដែលមិនមែនជាភាគីនៃរឿងក្តីក៏ដោយ*។ ពុំមានការកម្រិតថាតើនៅពេលណាដែលអង្គជំនុំជម្រះពាក់ព័ន្ធអាចចេញសេចក្តីបដិសេធបាន ទោះបីវាហាក់ដូចជា មានប្រយោជន៍ដល់

---

[24] គម្រោងយុត្តិធម៌ និង ច្បាប់សាធារណៈ, បញ្ហាផលប្រយោជន៍សាធារណៈ, ការកែទម្រង់ច្បាប់ និង ការអនុវត្តទៅលើការធ្វើអន្តរាគមន៍នៅក្នុងរឿងក្តីដែលមានផលប្រយោជន៍ជាសាធារណៈ (គម្រោងយុត្តិធម៌/ច្បាប់សាធារណៈ ១៩៩៦) ទំព័រទី ១៨ ។

[25] សូមមើល Dinah Shelton, ការចូលរួមរបស់អង្គការមិនមែនរដ្ឋាភិបាលនៅក្នុងដំណើរការនីតិវិធីតុលាការអន្តរជាតិ 88 AM. J INT'L L 611 (1994).

[26] *L'arrêt Gervaise* ចុះថ្ងៃទី១០ កក្កដា ១៩៥៧ (បកប្រែក្រៅផ្លូវការ)។

[27] ICTY ព័ត៌មានស្តីពីសេចក្តីណែនាំអនុវត្តទៅលើការដាក់សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី, IT/122, 27 March 1997 ("ICTY Information")។

[28] (មានសេចក្តីបញ្ជាក់បន្ថែម)។

សេចក្ដីកិច្ចរបស់តុលាការក្នុងការបដិសេធអ្នកដែលមិនមែនជាភាគីនៃរឿងក្ដីដែលបានស្នើសុំ មុនពេលដាក់សារណា។

**ឃ. កាតព្វកិច្ចចំពោះចៅក្រម**

17. វិធានផ្ទៃក្នុង ៣៤ ចែងថា៖

១. ចៅក្រមអាចដកខ្លួនឯងចេញពីករណីណាមួយ ដែលចៅក្រមរូបនោះមាន ឬ ធ្លាប់មានផលប្រយោជន៍ផ្ទាល់ខ្លួន ឬ ហិរញ្ញវត្ថុ ឬ មានការពាក់ព័ន្ធ ដែលអាចធ្វើអោយប៉ះពាល់យ៉ាងពិតប្រាកដដល់ភាពអនាគតិរបស់ចៅក្រមរូបនោះ ឬ អាចបង្កើតអោយមានភាពលំអៀង។ [...] ចៅក្រមដែលកំពុងមានបញ្ហាត្រូវឈប់ចូលរួមជាបន្ទាន់ ក្នុងកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះ។

18. នីតិវិធីសំរាប់ការប្ដឹងជំទាស់ចិត្ត និង អត្ថន័យនៃឃ្លា "មានការពាក់ព័ន្ធ ដែលអាចធ្វើអោយប៉ះពាល់ ភាពអនាគតិ[...]" និង "អាចបង្កើតអោយមានភាពលំអៀង" នៅក្នុងវិធានផ្ទៃក្នុងនេះត្រូវដោះស្រាយដោយអង្គបុរេជំនុំជម្រះ នៅក្នុងសេចក្ដីសំរេចរបស់ខ្លួនស្ដីពីសំណើសុំប្ដឹងជំទាស់ចិត្តលោកចៅក្រម **ន័យ ថុល** ដែលដាក់ប្ដឹងដោយសហមេធាវីរបស់ជនត្រូវចោទ **នួន ជា**[29] ។ អង្គបុរេជំនុំជម្រះ បានយល់ឃើញថា មាន "ការសន្មតទុកជាមុនអំពីភាពមិនលំអៀងដែលមានចំពោះចៅក្រមនៅ អ.វ.ត.ក[30] ហើយយល់ឃើញថា បន្ទុកមានចំពោះភាគីដែលធ្វើបណ្ដឹងជំទាស់ចិត្តក្នុងការបង្ហាញភស្តុតាងអោយបានគ្រប់គ្រាន់ ដើម្បីធ្វើអោយអង្គបុរេជំនុំជម្រះឃើញថា ចៅក្រមដែលកំពុងមានបញ្ហាអាចត្រូវបានគេយល់ឃើញថាមានភាពលំអៀង[31]។ អង្គបុរេជំនុំជម្រះ ក៏បានយល់ឃើញថា "ចៅក្រមមួយរូបត្រូវបានចាត់ទុកថាមានភាពលំអៀង ប្រសិនបើត្រូវបានរកឃើញថាមានសកម្មភាពលំអៀងពិតប្រាកដមែន[32]" ហើយថា មានការលំអៀងតាមរយៈការមើលឃើញពីខាងក្រៅ ប្រសិនបើ៖

---

[29] *រឿងក្ដី នួន ជា* ០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ០១) សេចក្ដីសម្រេចជាសាធារណៈស្ដីពីបណ្ដឹងជំទាស់ចិត្តជាបន្ទាន់របស់សហមេធាវីជនត្រូវចោទ នួន ជា ចំពោះលោកចៅក្រម ន័យ ថុល ចុះថ្ងៃទី ០៤ កុម្ភៈ ២០០៨ ("តទៅនេះហៅថា សេចក្ដីសម្រេចករណី *នួន ជា*") ។

[30] *ដូចយោងខាងលើ* កថាខណ្ឌ ១៥-១៧

[31] *ដូចយោងខាងលើ* កថាខណ្ឌ ១៩

[32] *ដូចយោងខាងលើ* កថាខណ្ឌ ២០.

- "ចៅក្រមមួយរូបជាភាគីនៃរឿងក្តី ឬមានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុ ឬទាក់ទងនឹងកម្មសិទ្ធិ ដែលបានមកពីរឿងក្តីនោះ ឬ ប្រសិនបើការសម្រេចសេចក្តីរបស់ចៅក្រម នឹងនាំអោយមានការគាំទ្រដល់រឿងក្តីមួយ ដែលរូបគាត់មានការពាក់ព័ន្ធជាមួយភាគីណាមួយនៃរឿងក្តីនោះ។ ក្នុងកាលៈទេសៈបែបនេះ ចៅក្រមរូបនោះ ត្រូវដកខ្លួនចេញពីរឿងក្តីនោះដោយស្វ័យប្រវត្តិ ឬ
- ក្នុងកាលៈទេសៈដែលអាចនាំអោយមានការកត់សម្គាល់មួយដ៏សមហេតុផលមួយ និងមានព័ត៌មានត្រឹមត្រូវចំពោះការយល់ដឹងអំពីការលំអៀងដោយសមហេតុផល។[33]"

19. អង្គបុរេជំនុំជម្រះបានអះអាងថា អ្នកកត់សម្គាល់ដ៏សមហេតុផលម្នាក់នៅក្នុងការបរិយាយខាងលើនេះគឺជា "បុគ្គលម្នាក់ដែលមានព័ត៌មានគ្រប់គ្រាន់ យល់ដឹងអំពីកាលៈទេសៈពាក់ព័ន្ធទាំងអស់ រាប់បញ្ចូលទាំងប្រពៃណីនៃសេចក្តីថ្លៃថ្នូរ និងភាពមិនលំអៀងដែលបង្កើតបានជាផ្នែកមួយនៃមូលដ្ឋាន និងការវាយតម្លៃអំពីអង្គហេតុផងដែលថា ភាពអនាគតិ គឺជាករណីកិច្ចមួយក្នុងចំណោមករណីកិច្ចផ្សេងទៀត ដែលចៅក្រមគ្រប់រូបត្រូវតែសច្ចាថាគាំទ្រលើកតម្កើងឡើង"[34]។

20. ពាក្យថា "មានការគាំទ្រដល់រឿងក្តី" នៅក្នុងការបរិយាយខាងលើត្រូវបានបកស្រាយក្នុងន័យទូលំទូលាយនៅកំរិតថ្នាក់ជាតិ ។ នៅក្នុងរឿងក្តី *រ៉ី ហូហ្វម៉ែន* (*re Hoffman*) ចៅក្រម ហូហ្វម៉ែន ដែលបានធ្វើជាចៅក្រមមានអាសនៈនៅតុលាការកំពូល (House of Lords) ដែលកាត់ក្តីលើបណ្តឹងសារទុក្ខទាក់ទងនឹងការឃុំខ្លួនឧត្តមសេនីយ៍ អូហ្គូសតូ ពីណូជេ (Augusto Pinochet) មានផលប្រយោជន៍មួយផ្នែកជាមួយនឹងអង្គការលើកលែងទោសអន្តរជាតិ (Amnesty International) ដែលបានចូលអន្តរាគមនៅក្នុងរឿងក្តី ដើម្បី "សន្និដ្ឋានថា មិនមានអភ័យឯកសិទ្ធិសំរាប់អតីតប្រមុខរដ្ឋ ទាក់ទងទៅនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[35]" ។ ផលប្រយោជន៍ជាបុគ្គលនេះ ដែលបង្កើតបានជា ការគាំទ្រដល់រឿងក្តី

---

[33] *ដូចយោងខាងលើ* ដកស្រង់ដោយយល់ស្របតាម រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង* *Furundžija* សំណុំរឿងលេខ IT-95-17/1-A សាលដីកា អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី ២១ កក្កដា ២០០០ កថាខណ្ឌ ១៨៩ (តទៅនេះហៅថា "សាលដីកា ហ្វូរ៉ាន់ហ្ស៊ីហ្សា (*Furundžija*)")។ យោងតាមអង្គបុរេជំនុំជម្រះ យុត្តិសាស្ត្រនេះត្រូវបានយកមកអនុវត្តជាទូទៅដោយតុលាការអន្តរជាតិ។

[34] *ដូចយោងខាងលើ* ដកស្រង់ដោយយល់ស្របតាម សាលដីកា ហ្វូរ៉ាន់ហ្ស៊ីហ្សា (*Furundžija*) កថាខណ្ឌ ១៩០ ។

[35] *ករណី In re Hoffman,* តុលាការកំពូលអង់គ្លេស (UK House of Lords) សាលដីកាដោយផ្ទាល់មាត់ ចុះថ្ងៃទី ១៧ ធ្នូ ១៩៩៨ សំអាងហេតុះ ១៥ មករា ១៩៩៩ នៅទំព័រ ១១

មានលក្ខណៈគ្រប់គ្រាន់ដែលបង្កើតបានទំនាស់ផលប្រយោជន៍ហើយឈានទៅដល់ការដកហូតសិទ្ធិរបស់គាត់ជាស្វ័យប្រវត្តិពីរឿងក្តីនេះ។

21. ករណីកិច្ចនៃអនាគតិដែលដាក់បន្ទុកមកលើចៅក្រមនៅ អ.វ.ត.ក ត្រូវបានពង្រឹងតាមរយៈការពិនិត្យពិច័យនូវមាត្រា ២ នៃក្រមសីលធម៌របស់ចៅក្រមដែលតម្រូវថា៖

១. ចៅក្រមត្រូវមានភាពមិនលំអៀង និង ត្រូវធានាពីការសំដែងអោយឃើញអ្វីមួយមិនលំអៀងក្នុងការបំពេញភារកិច្ចរបស់ខ្លួន។

២. ចៅក្រមត្រូវជៀសវៀងនូវរាល់ជម្លោះផលប្រយោជន៍ ឬ ស្ថិតក្នុងស្ថានភាពណាមួយដែលគេអាចយល់ឃើញថាមានជម្លោះផលប្រយោជន៍កើតឡើង[36]។

22. វាក៏ជាការផ្តល់ព័ត៌មានផងដែរ ដើម្បីពិចារណាថាតើបញ្ហានៃទំនាស់ផលប្រយោជន៍ត្រូវបានដោះស្រាយយ៉ាងដូម្តេចដោយតុលាការអតីតយូហ្គោស្លាវី (ICTY) ។ តុលាការនេះបានយល់ឃើញថា បើសិនជាតុលាការកំណត់នូវព្យសនកម្ម ដែលបង្កឡើងដោយទំនាស់ផលប្រយោជន៍ដែលវាបណ្តាលអោយមានគ្រោះថ្នាក់ដល់សិទ្ធិរបស់ជនជាប់ចោទ ក្នុងការទទួលបាននូវសវនាការឆាប់រហ័សនិងប្រកបដោយយុត្តិធម៌ ឬ ការគ្រប់គ្រងវិស័យយុត្តិធម៌ដ៏ត្រឹមត្រូវ នោះតុលាការនឹងចាត់វិធានការចាំបាច់ និង សមរម្យដើម្បីស្រោចស្រង់ និងការពារភាពយុត្តិធម៌នៃការជំនុំជម្រះក្តី និងសុច្ចរិតភាពនៃនីតិវិធី[37] ។ ក្នុងករណីនេះ វាមានសារៈសំខាន់ដើម្បីបង្កានូវទំនាស់ផលប្រយោជន៍នៅមុនពេលដែលវាកើតមានឡើង[38]។

## IV. ទឡ្ហីករណ៍

### A. *អ្នកដែលមិនមែនជាភាគីនៃរឿងក្តី (amicus curiae)*

---

[36] អនុម័តដោយកិច្ចប្រជុំពេញអង្គនៃអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា កាលពីថ្ងៃទី ៣១ មករា ២០០៨ ។ *សូមមើលផងដែរ* មាត្រា ៤ នៃក្រមសីលធម៌ចៅក្រមរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលព័ណនាករណីកិច្ចនៃអនាគតិជាពាក្យពេជន៍តែមួយដូចគ្នា ។

[37] *រដ្ឋអាជ្ញា តទល់នឹង Prlić et al.,* សំណុំរឿងលេខ IT-04-74PT, សេចក្តីសំរេចលើសំណើសុំអោយតែងតាំងមេធាវី ចុះថ្ងៃទី ៣០ កក្កដា ២០០៤ កថាខណ្ឌ ១៦ ។

[38] រដ្ឋអាជ្ញា ទតល់នឹង *Gotovina et al,* សំណុំរឿងលេខ IT 06-90-AR73.2, សេចក្តីសម្រេចបណ្តឹងឧទ្ធរណ៍មុនអង្គសេចក្តីរបស់ Ivan Čermak ប្រឆាំងនឹងសេចក្តីសំរេចរបស់អង្គជំនុំជម្រះតុលាការដំបូងស្តីពីទំនាស់ផលប្រយោជន៍របស់មេធាវី Čedo Prodanović និង Jadranka Sloković ចុះថ្ងៃទី ២៨ មិថុនា ២០០៧ កថាខណ្ឌ ១៦ ។

23. សាស្ត្រាចារ្យ **កាសេស៊ី** (Cassese) មានការលំអៀងទៅលើបញ្ហានៃការកកើតនៃ ការទទួលខុសត្រូវជាទម្រង់សហកម្មឧក្រិដ្ឋកម្មរួម នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ និងទៅលើការអនុវត្តន៍ទម្រង់នៃការទទួលខុសត្រូវនេះនៅ អ.វ.ត.ក សំរាប់ហេតុផលដូចមានចែងខាងក្រោម។ នៅក្នុងបរិបទនៃបញ្ហាដែលកំណត់នៅក្នុងសេចក្តីអញ្ជើញ អនាគតិមានន័យដូចតទៅ៖ ទីមួយ អនាគតិ មានន័យថា កង្វះនូវផលប្រយោជន៍ណាមួយនៅក្នុងការសន្និដ្ឋាន ដែលមានទំនោរទៅរក ឬ ប្រឆាំងនឹងការអនុវត្តន៍សហកម្មឧក្រិដ្ឋកម្មរួម នៅកំឡុងឆ្នាំ ១៩៧៥ ដល់ ១៩៧៩ ។ ទីពីរ អនាគតិ មានន័យថា លទ្ធភាពដើម្បីដោះស្រាយនូវបញ្ហាដែលកំណត់នៅក្នុងសេចក្តីអញ្ជើញ ដោយគំនិតទូលំទូលាយ។ ទីបី លទ្ធភាពដូចដែលអ្នកដែលមិនមែនជាភាគីនៃរឿងក្តីមានតែមួយដែលត្រូវបានអញ្ជើញដោយអង្គបុរេជំនុំជម្រះដើម្បីកំណត់បង្ហាញអោយបានច្បាស់ ចង្អុលចរិកលក្ខណៈ និង ពិនិត្យពិច្ច័យនូវទស្សនៈរបស់អ្នកដទៃទៀត។ សាស្ត្រាចារ្យ **កាសេស៊ី** (Cassese) មានការលំអៀង នៅពេលជំរះសេចក្តីប្រឆាំងនឹងចំណុចទាំងអស់នេះដែលមានលក្ខណៈវិនិច្ឆ័យជាមូលដ្ឋានបំផុត។

24. ដូចដែលការកត់សំគាល់ជំហានដំបូងរបស់មេធាវីការពារដែលគួសចំណាំថា ការពិតដែល សាស្ត្រាចារ្យ **កាសេស៊ី** (Cassese) ត្រូវបានអញ្ជើញអោយដាក់សារណា *អ្នកដែលមិនមែនជាភាគី* ជាលាយលក្ខណ៍អក្សរ "ដែលជានិពន្ធនាយក"សម្រាប់ ទនានុប្បវត្តិ[39] <u>មិនបាន</u>បំបាត់ចោលនូវការតតាំងនឹងអនាគតិរបស់គាត់ឡើយ។ ទោះបីជា សរសេរក្នុងនាមជាបុគ្គលផ្ទាល់ខ្លួន ឬ នៅក្នុងនាមជាចៅក្រមនៅតុលាការអតីតយូហ្គោស្លាវី ICTY ការអនុវត្តន៍នូវ សហកម្មឧក្រិដ្ឋកម្មរួម ជាច្បាប់ទំនៀមទម្លាប់អន្តរជាតិគឺជាស្នូលនៃកេរ្តិ៍ឈ្មោះរបស់សាស្ត្រាចារ្យ **កាសេស៊ី** (Cassese)។ ហេតុដូច្នេះសេក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សររបស់គាត់ទៅលើបញ្ហានេះនឹងដូចតែគ្នា ដោយមិនគិតអំពីគុណសម្បត្តិជាអ្វីដែលគាត់ប្រើការតាក់តែងនូវសារណានេះ [40]។ ការពិតដែលថា សារណាជា

---

[39] សេចក្តីអញ្ជើញ ទំព័រទី ៣ ។

[40] ការពិត ខណៈដែល សាស្ត្រាចារ្យ **កាសេស៊ី** (Cassese) គឺជាអ្នកនិពន្ធនៃសៀវភៅដែលនឹងចេញផ្សាយនាពេលខាងមុខរបស់ Oxford Companion to International Criminal Justice. *សូមមើល* ANTONIO CASSESE (ED.) THE OXFORD COMPANION TO INTERNATIONAL CRIMINAL JUSTICE (OXFORD, 2008 ដែលគ្រោងនឹងបោះពុម្ពនៅថ្ងៃទី ៩ តុលា ២០០៨ ។ ផ្នែកទាក់ទងនឹង សហកម្មឧក្រិដ្ឋកម្មរួម នៅក្នុងសៀវភៅនេះត្រូវព្រាងដោយ Katrina Gustafson នៃការិយាល័យអយ្យការ ICTY ជាអ្នកដែលពីមុនបានសរសេរអត្ថបទជាប្រយោជន៍ចំពោះការប្រើប្រាស់ និងការពង្រីកការទទួលខុសត្រូវព្រហ្មទណ្ឌនៃ សហកម្មឧក្រិដ្ឋកម្មរួម ។ *សូមមើល* Katrina Gustafson *តម្រូវការនៃ"ការព្រមព្រៀងរបស់" សំរាប់សហកម្មឧក្រិដ្ឋកម្មរួម ៖ ការតិទៀនរឿងក្តី Brdanin,* 5 Journal of International Criminal Justice 134-158 (2007)។

លាយលក្ខណ៍អក្សររបស់គាត់អាចនឹងត្រូវចុះហត្ថលេខាក្នុងនាមជា និពន្ធនាយកសម្រាប់ ទនានុប្បវត្តិ មិនធ្វើអោយមានការខុសប្លែកគ្នាចំពោះបញ្ហាអនាគតិ[41]។ សមត្ថភាពវិជ្ជាជីវៈរបស់សាស្ត្រាចារ្យ **កាសេស៊ី** (Cassese) ជាអតីតចៅក្រមនៅតុលាការអតីតយូហ្គោស្លាវី ICTY ដែលបានច្នៃប្រឌិត សហកម្មឧក្រិដ្ឋកម្មរួម និងសមត្ថភាពបច្ចុប្បន្នរបស់គាត់ជានិពន្ធនាយកសម្រាប់ *ទនានុប្បវត្តិ* គឺមិនអាចញែកដាច់ពីគ្នាបានក្នុងន័យនៃខ្លឹមសារនៃសារណាជាលាយលក្ខណ៍អក្សរដែលគាត់នឹងដាក់ជូន ។ ដោយស្នើអ្វីផ្សេងពីនេះគឺ គ្មានន័យអ្វីសុទ្ធសាធ។

**1. សាស្ត្រាចារ្យ កាសេស៊ី (Cassese) និង សមាជិកនិពន្ធមួយចំនួនមានផលប្រយោជន៍ដែលអាចចង្អុលបង្ហាញបាន ដើម្បីផ្តល់នូវចម្លើយជាវិជ្ជមានចំពោះចម្ងល់ដែលថា តើសហកម្មឧក្រិដ្ឋកម្មរួម អនុវត្តនៅ អ.វ.ត.ក ចំពោះឧក្រិដ្ឋកម្មដែលចោទប្រកាន់ថាបានប្រព្រឹត្តក្នុងរវាងឆ្នាំ ១៩៧៥ ដល់ ១៩៧៩ ដែរឬទេ**

25. សាស្ត្រាចារ្យ **កាសេស៊ី** (Cassese) មានផលប្រយោជន៍ដែលអាចចង្អុលបង្ហាញបាន និងច្បាស់លាស់ ដើម្បីផ្តល់នូវចម្លើយជាវិជ្ជមានយ៉ាងហោចណាស់ទាក់ទងនឹងបញ្ហាទីពីរ ស្នើដោយអង្គបុរេ គឺ "ថាតើ សហកម្មឧក្រិដ្ឋកម្មរួម ដែលជាទម្រង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌអាចត្រូវបានអនុវត្តនៅ អ.វ.ត.ក ដោយពិចារណាអំពីអង្គហេតុថា ឧក្រិដ្ឋកម្មទាំងនេះត្រូវបានប្រព្រឹត្តនៅក្នុងរយៈពេលពីឆ្នាំ ១៩៧៥ ដល់ ១៩៧៩" [42]។

26. ការប្រើប្រាស់នូវច្បាប់ទំនៀមទម្លាប់អន្តរជាតិដើម្បីបង្កើតនូវ សហកម្មឧក្រិដ្ឋកម្មរួម ថាជាទម្រង់នៃការទទួលខុសត្រូវខាងព្រហ្មទណ្ឌនៅក្នុងករណី *តាឌិច* (*Tadić*) បានក្លាយជាប្រធានបទសម្រាប់ការរិះ

---

ការអនុញ្ញាតអោយមានផ្នែកសំខាន់បែបនេះនៅក្នុងសៀវភៅសំរាប់យោងដោយសន្មតថាមិនលំអៀង ដូចជា Oxford Companion ដែលនឹងត្រូវព្រាងដោយមនុស្សម្នាក់នៅឆ្ងាយពីភាពមិនលំអៀង ទៅលើប្រធានបទ គឺគ្មានអ្វីក្រៅពីភាពមិនស្មោះត្រង់ខាងបញ្ញា។ វាក៏ត្រូវយល់ព្រមអោយហួសពីការសង្ស័យ ដែលថា កង្វះខាតនៃអនាគតិរបស់សាស្ត្រាចារ្យ **កាសេស៊ី** (Cassese)ទៅលើប្រធានបទនេះ ពង្រីកសមត្ថភាពបច្ចុប្បន្នរបស់គាត់ក្នុងថាជានិពន្ធនាយកនៃទិន្នានុប្បវត្តិ។

[41] នៅក្នុងករណីនេះ ការវែកញែករបស់អង្គបុរជំនុំជម្រះនៅក្នុងសេចក្តីសម្រេចករណី ***នួន ជា*** រវាងការតែងតាំងចៅក្រម **ន័យ ចុល** ក្នុងសមត្ថភាពផ្ទាល់ខ្លួន ជាជាងសមត្ថភាពវិជ្ជាជីវៈ <u>មិនអនុវត្ត</u> ក្នុងន័យដូចគ្នានៅទីនេះទេ ។ *សូមមើល សេចក្តីសំរេចករណី* ***នួន ជា*** កថាខណ្ឌ ២៤ ។

[42] សេចក្តីអញ្ជើញ ទំព័រទី ១ ។

គន់ជាច្រើន[43]។ ការពឹងផ្អែកលើរឿងក្តីជនជាតិអ៊ីតាលីដែលមិនច្បាស់លាស់ និង ការខ្វាត់ខ្វាយនៃយុត្តិសាស្ត្រនៃករណីសង្គ្រាមលោកលើកទី ២ ដើម្បីប្រកាសពីការកកើតនៃសហកម្មឧក្រិដ្ឋកម្មរួមនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ចង្អុលបង្ហាញនូវការយល់ដឹងដែលគេទទួលយកថាតើច្បាប់ទំនៀមទម្លាប់អន្តរជាតិត្រូវបានបង្កើតឡើង[44]។ ដោយមិនគួរអោយជឿរជាក់បាន អង្គជំនុំជម្រះតុលាការកំពូលបានរកឃើញនូវ បទដ្ឋានប្រពៃណី ក្រៅពីការទទួលស្គាល់ថា ប្រព័ន្ធច្បាប់ municipal

---

[43] *សូមមើល* សៀវភៅរបស់ ALEXANDER ZAHAR & GÖRAN SLUITER, ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ៖សេចក្តីផ្តើមដែលមានសារៈសំខាន់ (Oxford, 2007) (តទៅនេះហៅថា "សៀវភៅរបស់ ZAHAR & SLUITER")។ អត្ថបទរបស់ Stephen Powles ស្តីពី *ការទទួលខុសត្រូវព្រហ្មទណ្ឌតាមរយៈភាពមិនប្រសព្វនៃការចោទប្រកាន់ និងការច្នៃប្រឌិតរបស់តុលាការ?* 2 JICJ, 606 (2004)។ អត្ថបទរបស់ Mohamed Elewa Badar ក្រោមចំណងជើងថា "ផ្តន្ទាទោសមនុស្សគ្រប់រូប" (Just Convict Everyone!) - *ការប្រព្រឹត្តរួមគ្នា៖ ចាប់ពី Tadić ទៅដល់ Stakić ការត្រឡប់មកវិញ* 293 Int'l Crim. L. Rev. 301 (2006) ។ អត្ថបទរបស់ Atilla Bogdan ក្រោមចំណងជើងថា *ការទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គល នៅក្នុងការអនុវត្តនូវ "សហកម្មឧក្រិដ្ឋកម្មរួម"* នៅក្នុងយុត្តិសាស្ត្រនៃតុលាការអន្តរជាតិចំពោះកិច្ចសំរាប់អតីតយូហ្គោស្លាវី 6 ICLR (2006) 63 ។ *រដ្ឋអាជ្ញា តទល់នឹង* *Stakić* សំណុំរឿងលេខ IT-97-24-T សាលក្រមចុះថ្ងៃទី ៣១ កក្កដា ២០០៣ (តទៅនេះហៅថា "សាលដីកាក្នុងរឿងក្តី *Stakić*") កថាខណ្ឌ ៤៣៣ នៅពេលដែលអង្គជម្រះជាន់ដំបូងបានព្រមានថា ការបកស្រាយដោយពង្រីកចំពោះ សហកម្មឧក្រិដ្ឋ-កម្មរួម ប្រាកដជាអាចឈានទៅដល់ "ការរំលោភបំពានជាក់ស្តែងចំពោះគោលការណ៍*គ្មានបទល្មើសបើគ្មានច្បាប់ចែង* (*nullum crimen sine lege*)"។ *រដ្ឋអាជ្ញា តទល់នឹង Simić* សំណុំរឿងលេខ IT-95-9/2-T សាលក្រម ចុះថ្ងៃទី ១៧ តុលា ២០០២ យោបល់ដោយឡែក *ad-litem* របស់ចៅក្រម Per-Johan Lindholm កថាខណ្ឌ ២ ដល់ ៥ ដែលចៅក្រម Lindholm បាននិយាយថា គាត់ "មិនចង់ពាក់ព័ន្ធ" ខ្លួនគាត់ជាមួយនឹង សហកម្មឧក្រិដ្ឋកម្មរួម ដោយកត់សំគាល់ថា "ទស្សនាទាន ឬ ទ្រឹស្តីនេះ បានបង្កអោយមានការភ័ន្តច្រលំ និង ចំណាយពេលឥតប្រយោជន៍ ហើយជាយោបល់របស់ខ្ញុំគឺមិនមានអត្ថប្រយោជន៍ដល់កិច្ចការតុលាការ ឬ ការអភិវឌ្ឍន៍នូវច្បាប់ព្រហ្មទណ្ឌអន្តរជាតិឡើយ"។

[44] *សូមមើល* អត្ថបទរបស់ ILIAS BANKETAS & SUSAN NASH ក្រោមចំណងជើងថា **ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ** ទំព័រ ៣៣ (បោះពុម្ពលើកទី ៣ ឆ្នាំ ២០០៧) ដោយប្រកាសថា វា"មិនអាចទទួលយកបានសំរាប់តុលាការក្នុងការអះអាងនូវសុពលភាពនៃការស្ថាបនាច្បាប់នេះស្តីពីច្បាប់ទំនៀមទំលាប់ដែលបានប្រកាសយ៉ាងច្បាស់ក្រឡែត ... វាមិនគួរត្រូវគេសន្មតយ៉ាងខ្ពង់ខ្ពស់ (ដោយថ្លែងថា សហកម្មឧក្រិដ្ឋកម្មរួម គឺជាបទដ្ឋានទំនៀមទំលាប់) ដែលវាក៏ជាការពិត និង ចុងបញ្ចប់នៅក្រៅពីក្របខណ្ឌរបស់តុលាការអតីតយូហ្គោស្លាវី ICTY" ។ ការតិទៀនមួយចំនួនលើទ្រង់ទ្រាយនៃសេចក្តីសំរេចនេះក៏បានកើតចេញពីខាងក្នុងតុលាការអតីតយូហ្គោស្លាវី ICTY នេះខ្លួនឯងទៀតផង។ សំរាប់ជាឧទាហរណ៍ នៅក្នុងករណី *Stakic* អង្គជំនុំជម្រះតុលាការដំបូងបានប្រើប្រាស់ជារឿងថ្មី (*de novo*) នូវទ្រឹស្តីនៃការប្រព្រឹត្តរួមគ្នាថាជាទម្រង់ផ្សេងនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ខណៈដែលបានសំដែងក្តីមន្ទិលទៅលើធម្មនុរូបនៃ សហកម្មឧក្រិដ្ឋកម្មរួម ដែលត្រូវបានបង្កើតនៅក្នុងរឿងក្តី **តាឌិច** ។ (សាលដីកាក្នុងរឿងក្តី *Stakić* កថាខណ្ឌ ៤៣៨, ៤៤១)។

មានលក្ខណៈខុសប្លែកយ៉ាងសំខាន់ពីសុពលភាពនៃប្រភេទទីបីនៃ សហកម្មឧក្រិដ្ឋកម្មរួម[45]។ ការមិនមានឆន្ទះបែបនេះដើម្បីទទួលយកជាទូទៅនូវគោលការណ៍ដែលគេទទួលស្គាល់ថាតើ ទំនៀមទំលាប់ត្រូវបានបង្កើតយ៉ាងដូចម្តេចគឺជាបញ្ហាស្មុគស្មាញជាក់លាក់ដោយសារសារជាតិនៃបញ្ហាដែលសាស្ត្រាចារ្យ **កាសេស៊ី** (Cassese) ត្រូវបានគេចោទសួរ ដើម្បីអះអាងបញ្ជាក់នៅចំពោះ អ.វ.ត.ក[46] ។

---

[45] សាលក្រម កថាខណ្ឌ ២២៤ ។ មាត្រា ៣៨(១) នៃលក្ខន្តិកៈតុលាការយុត្តិធម៌អន្តរជាតិ (ICJ) សំដៅ "ទំលាប់អន្តរជាតិដែលជាភស្តុតាងការអនុវត្តជាទូទៅទទួលយកថាជាច្បាប់"។ ទម្លាប់អនុវត្តរបស់រដ្ឋ (state practice) មានន័យជាសំខាន់ថា ការអនុវត្តដែលមិនផ្លាស់ប្តូរ និងជាទូទៅ ខណៈដែល ទង្វើរបស់រដ្ឋចាំបាច់តាមនីតិរដ្ឋ *(opinio juris)* មានន័យថា ការអនុវត្តដែលយកតាមជំនឿនៃកាតព្វកិច្ចផ្លូវច្បាប់ *សូមមើល* អត្ថបទរបស់ Ian Brownlie គោលការណ៍នៃច្បាប់អន្តរជាតិសាធារណៈ ទំព័រ ៤ ដល់ ១១ (បោះពុម្ពលើកទី ៥ ឆ្នាំ ១៩៩៨)។ និយមន័យនេះត្រូវបានព្រមទទួលយកយ៉ាងទូលំទូលាយ និងត្រូវបានយកទៅប្រើប្រាស់ដោយតុលាការយុត្តិធម៌អន្តរជាតិ (ICJ) នៅក្នុងរឿងក្តីជាច្រើន រួមមាន *រឿងក្តី North Sea Continental Shelf* 1969 I.C.J. 3, 44 (Feb. 20 1969) ។ *សកម្មភាពយោធា និងយោធាប្រតិព័ទ្ធ នៅក្នុង និងប្រឆាំងនឹងប្រទេសនីការ៉ាហ្គ័រ* (ប្រទេសនីការ៉ាហ្គ័រ តទល់នឹង សហរដ្ឋអាមេរិច) អង្គសេចក្តី 1986 I.C.J. a14 (June 27, 1986) នៅទំព័រ ៩៨ ដែល តុលាការយុត្តិធម៌អន្តរជាតិ (ICJ) បានថ្លែងថា ទង្វើរបស់រដ្ឋចាំបាច់តាមនីតិរដ្ឋ *(opinio juris)* ត្រូវតែអះអាងបញ្ជាក់ដោយទម្លាប់អនុវត្តរបស់រដ្ឋ។ សហកម្មឧក្រិដ្ឋកម្មរួម ត្រូវបានគេតិទៀនដោយសារមិនបានបំពេញនូវលក្ខណៈវិនិច្ឆ័យទាំងពីរនេះ ។ ចៅក្រម **ស្កូមប៊ើក** (Schomburg) នៅក្នុងយោបល់ជំទាស់របស់គាត់នៅក្នុងរឿងក្តី **ស៊ីមិច** (*Simić*) ដោយកត់សំគាល់ថា "នៅប្រព័ន្ធច្បាប់ដទៃទៀត ការប្រព្រឹត្តត្រូវបានបកស្រាយផ្សេងពីយុត្តិសាស្ត្រនៃអង្គជំនុំជម្រះ។ ចាប់តាំងពីតុលាការនៅ **ណូរ៉ែមប៊ើក** និង នៅ **តូក្យូ** ទាំងច្បាប់ព្រហ្មទណ្ឌជាតិ និងអន្តរជាតិបានព្រមទទួលយក ជាពិសេស ការប្រព្រឹត្តរួមគ្នា (co-perpetratorship) ថាជាទម្រង់មួយនៃការប្រព្រឹត្ត" *រដ្ឋអាជ្ញា តទល់នឹង Simić* សំណុំរឿង IT-95-9-A យោបល់ជំទាស់របស់ចៅក្រម **ស្កូមប៊ើក** (Schomburg) ចុះថ្ងៃទី ២៨ វិច្ឆិកា ២០០៦ (តទៅនេះហៅថា "យោបល់ជំទាស់រឿងក្តី *Simić*") កថាខណ្ឌ ១៤ ។ ចៅក្រម **ស្កូមប៊ើក** (Schomburg) បានធ្វើបញ្ជីប្រទេសចំនួន ២៤ រាលដាលពាសពេញពិភពលោក លើកជាឧទាហរណ៍នៃការប្រើប្រាស់នូវ ការប្រព្រឹត្តរួមគ្នា ។ *សូមមើល* យោបល់ជំទាស់រឿងក្តី *Simić* កថាខណ្ឌ ១៣, ១៤ ។ គាត់ផ្អែកការរកឃើញរបស់គាត់ ក្នុងចំណោមអ្វីផ្សេងទៀត ទៅលើការសិក្សានៃដែលធ្វើឡើងដោយវិទ្យាស្ថាន Max-Planck institute ដែលផ្តល់ដោយការិយាល័យអយ្យការរបស់តុលាការអតីតយូហ្គោស្លាវី ICTY ដោយបង្ហាញថា រដ្ឋភាគច្រើនលើសលប់ប្រើប្រាស់ ការប្រព្រឹត្តរួមគ្នា ជាជាងប្រើប្រាស់ សហកម្មឧក្រិដ្ឋកម្មរួម ។ *សូមមើល* **ការចូលរួមប្រព្រឹត្តបទល្មើស៖ ការទទួលខុសត្រូវព្រហ្មទណ្ឌនៃថ្នាក់ដឹកនាំទៅលើក្រុម និងបណ្តាញឧក្រិដ្ឋកម្ម** យោបល់នៃអ្នកឯកទេស ដែលផ្តល់ដោយអង្គការសហប្រជាជាតិ តុលាការព្រហ្មទណ្ឌអន្តរជាតិសំរាប់អតីតយូហ្គោស្លាវី គម្រោងសម្របសម្រួលនៃការិយាល័យរដ្ឋអាជ្ញា ដែលធ្វើឡើងដោយ សាស្ត្រាចារ្យបណ្ឌិត Ulrich Sieber., Priv. Doz. បណ្ឌិត Hans Georg Koch, Jan Michael Simon, នៃវិទ្យាស្ថាន Max Planck Institut für ausländisches und internationales Strafrecht, Freiburg, នៃប្រទេស អាល្លឺម៉ង់ ។

[46] ការអនុវត្តនូវគោលការណ៍ទូទៅនៃច្បាប់អន្តរជាតិសាធារណៈដោយ សាស្ត្រាចារ្យ **កាសេស៊ី** (Cassese)ត ក៏ប្រហែលជាគួរអោយសង្ស័យផងដែរ ។ ជាផ្នែកមួយនៃអង្គជំនុំជម្រះតុលាការកំពូលក្នុង រឿងក្តី **តាឌិច** គាត់បានពឹងផ្អែកទៅលើការបកស្រាយនៃទូរបាតុភូតសាស្ត្រ(teleological) លើលក្ខន្តិកៈតុលាការអតីតយូហ្គោស្លាវី ICTY ប៉ុន្តែបានបំភ្លេចនូវបញ្ញត្តិជាសារវន្តក្នុងការ

ច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅក្នុងរឿងក្តី **តាឌិច** (*Tadić*) ត្រូវបានព័ណ៌នាដោយមិនមានការភ្ញាក់ផ្អើលថាជា "ទស្សនៈដែលងាយស្រួលប្តូរទ្រង់ទ្រាយបំផុត"[47] ។

27. បើសិនសារណាជាលាយលក្ខណ៍អក្សរអះអាងថា សហកម្មឧក្រិដ្ឋកម្មរួម គឺជាចំណែកមួយនៃច្បាប់ទំនៀមទំលាប់អន្តរជាតិ ក្នុងរវាងឆ្នាំ ១៩៧៥ ដល់ ១៩៧៩ ដែលជាបញ្ហាមួយក្នុងចំនោមបញ្ហាសំខាន់នៅក្នុងបណ្តឹងឧទ្ធរណ៍របស់ ក.ស.ព ការណ៍នេះនឹងដាក់សាស្ត្រាចារ្យ **កាសេស៊ី** (Cassese) ដាកចេញពីការរិះគន់ដែលគាត់បានទទួលរង ។ វាក៏នឹងធានាអោយមាននូវកេរ្តិ៍ដំណែលរបស់សាស្ត្រាចារ្យ **កាសេស៊ី** (Cassese)។ ការណ៍នោះមិនមានន័យថា វាជាសេចក្តីថ្លែងការណ៍ត្រឹមត្រូវរបស់ច្បាប់ឡើយ។

## 2. សាស្ត្រាចារ្យ កាសេស៊ី (Cassese) និង គណៈកម្មាធិការនិពន្ធនាយក មិនមានលទ្ធភាពដើម្បីដោះស្រាយបញ្ហាដែលកំណត់ដោយអង្គបុរេជំនុំជម្រះដោយគំនិតទូលំទូលាយនោះទេ

---

ធ្វើបែបនោះ ។ ការពន្យល់នូវចំណុចនេះត្រូវព័ណ៌នាថាជា "ការអះអាងមួយក្នុងចំណោមការអះអាងគួរអោយកត់សំគាល់បំផុតនៅក្នុងប្រវត្តិសាស្ត្រនៃតុលាការ" ZAHAR & SLUITER ទំព័រ ២២៦ ។ នេះមិនមែនគ្រាន់តែជាវេលាមួយដែល សាស្ត្រាចារ្យ **កាសេស៊ី** (Cassese) បានផ្តល់នូវអ្វីមួយដែលជាការបកស្រាយដ៏ចម្រូងចម្រាស់លើច្បាប់ទំនៀមទម្លាប់អន្តរជាតិ ។ នៅក្នុងបរិបទដែលថាតើមានដូច្នេះមែនឬក៏អត់ ដែលមានការព្រមទទួលយកជាទូទៅនិយមន័យនៃភេរវកម្មនៅក្នុងច្បាប់អន្តរជាតិ អ្នកប្រាជ្ញជាភាគច្រើនទទួលយកថា ទម្លាប់អនុវត្តរបស់រដ្ឋ និង ទង្វើរបស់រដ្ឋចាំបាច់តាមនីតិរដ្ឋ *(opinio juris)* គឺត្រូវបែងចែកពីគ្នាជាខ្លាំងទៅប្រធានបទខាងលើនេះដើម្បីឆ្លើយតបនឹងករណីនេះ។ សាស្ត្រាចារ្យ **កាសេស៊ី** (Cassese) នឹងមិនអើពើនឹងចំនុចនេះ។ អត្ថិភាពនៃសន្ធិសញ្ញាជាច្រើនស្តីពីប្រធានបទនេះគឺគ្រប់គ្រាន់។ សាស្ត្រាចារ្យ **កាសេស៊ី** (Cassese) ផ្តល់នូវយុត្តិកម្មថា " វាត្រូវបានធានាដើម្បីមានជំនឿថា (បណ្តាសន្ធិសញ្ញាបច្ចុប្បន្ន) ទាំងដោយដឹងខ្លួនជាមុន ឬទាំងដោយមិនដឹងខ្លួនជាមុន បាននឹងកំពុងយោងទៅលើសញ្ញាណទូទៅដែលមាននៅចែងក្នុងបណ្តាបញ្ញត្តិនៃសន្ធិសញ្ញា និងមានចែងក្នុងវិធាននៃទំនៀមទំលាប់"។ ដោយនិយាយថា ការអះអាងបែបនេះដកហូតសេរីភាពខ្លះតាមរយៈសញ្ញាណនៃអ្វីដែលបង្កើតបានជាបទដ្ឋានទំនៀមទំលាប់ គឺជាអ្វីដែលជាការនិយាយមិនអស់សេចក្តី។ *សូមមើល* អត្ថបទរបស់ ROBERT BARNIDGE JR ក្រោមចំណងជើងថា **តួអង្គមិនមែនជារដ្ឋ និង ភេរវកម្ម ការអនុវត្តច្បាប់នៃការទទួលខុសត្រូវរបស់រដ្ឋ និងគោលការណ៍វិរិយភាពដ៏ត្រឹមត្រូវ** ទំព័រ ២៧ (Cambridge, 2007) ។ សំរាប់ការឆ្លើយតបទៅនឹងរឿងនេះ សូមមើល អត្ថបទរបស់ Ben Saul *ឧក្រិដ្ឋកម្ម និងការហាមឃាត់ "ភេរវក" និង "អំពើភេរវកម្ម" នៅក្នុងជម្លោះប្រដាប់អាវុធ 1919-2005* 18 Humanitäres Völkerrecht 264 នៅ 270-71(2005)។

[47] អត្ថបទរបស់ ZAHAR & SLUITER, ទំព័រ ២៣១

28. ជំហររបស់ សាស្ត្រាចារ្យ **កាសេស៊ី** (Cassese) ស្តីពី សហកម្មឧក្រិដ្ឋកម្មរួម គឺជាក់ច្បាស់យ៉ាងធ្ងន់ធ្ងរ តាមរយៈរឿងក្តី **តាឌិច** (*Tadić*) និង អត្ថបទស្រាវជ្រាវជាន់ខ្ពស់ជាបន្តបន្ទាប់របស់គាត់ដែលគាំទ្រ និង ដែលយល់ស្របនឹងទ្រឹស្តី និងភាពយូរអង្វែងនៃ សហកម្មឧក្រិដ្ឋកម្មរួម[48] ។ សាស្ត្រាចារ្យ **កាសេស៊ី** (Cassese) បានសរសេរថា តុលាការសំរាប់អតីតយូហ្គោស្លាវី ICTY បានរួមចំណែកដល់ "ច្បាប់ព្រហ្មទណ្ឌអន្តរជាតិទូទៅ" ដោយសង្កត់ធ្ងន់នូវបញ្ហាជាសារវ័ន្តដូចជា សហកម្មឧក្រិដ្ឋកម្មរួម[49] ជាដើម ។ ការណ៍នេះមិនបានធ្វើអោយមានជាការមន្ទិលសង្ស័យទៅលើសុពលភាពនៃ សហកម្មឧក្រិដ្ឋកម្មរួម ថាជាទម្រង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌ ដោយគាត់បានភ្ជាប់យ៉ាងជាក់ច្បាស់ទៅនឹងទ្រឹស្តីដែលអធិប្បាយនៅក្នុង រឿងក្តី **តាឌិច** ដែល សហកម្មឧក្រិដ្ឋកម្មរួមត្រូវបានបង្កើតជាចាំបាច់[50] ។ សាស្ត្រាចារ្យ **កាសេស៊ី** (Cassese) ធ្លាប់ជាសមាជិកម្នាក់នៃអង្គជំនុំជម្រះតុលាការកំពូលដែលជំនុំជម្រះរឿងក្តីនេះ [51]។ ថ្វីបើមានការរិះគន់ពី សហកម្មឧក្រិដ្ឋកម្មរួមក៏ដោយសាស្ត្រាចារ្យ **កាសេស៊ី** (Cassese) នៅតែសម្តែងមតិយ៉ាងក្លៀវក្លា និងតស៊ូមតិយ៉ាងម៉ឺងម៉ាត់ចំពោះទំរង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌដ៏ចម្រូងចម្រាស់ដែលគាត់ជាអ្នកបង្កើតវា ។

---

48 សូមមើល ជាឧទាហរណ៍ អត្ថបទរបស់ Antonio Cassese ក្រោមចំណងជើងថា *ការដាក់កំរិតដ៏ត្រឹមត្រូវនៃការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គលក្រោមទ្រឹស្តីនៃសហកម្មឧក្រិដ្ឋកម្មរួម* ៥ ទិនានុប្បវត្តិនៃយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ (២០០៧) ទំព័រ ១០៩ (តទៅនេះហៅថា "អត្ថបទរបស់ **កាសេស៊ី**") ។ អត្ថបទរបស់ ANTONIO CASSESE ក្រោមចំណងជើងថា **ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ** (Oxford ២០០៣) ។ អត្ថបទរបស់ Antonio Cassese ក្រោមចំណងជើងថា *តុលាការសំរាប់អតីតយូហ្គោស្លាវី ICTY៖ ការស្ថិតនៅ និងភាពជាការពិតជាសារវន្ត* ២ ទិនានុប្បវត្តិនៃយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ (២០០៤) ទំព័រ ៥៨៥ ។

49 *ដូចយោងខាងលើ* (២០០៤) ទំព័រ ៥៨៤ ដល់ ៥៨៥ ។

50 សាលដីកាក្នុងរឿងក្តី **តាឌិច** កថាខណ្ឌ ១៨៥ ដល់ ២៣៤ ។

51 អង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្តី **តាឌិច** មានចៅក្រម Mohamed Shahabuddeen ប្រធានក្រុមប្រឹក្សាជំនុំជម្រះ ។ ចៅក្រមបីរូបផ្សេងទៀត រួមមាន ចៅក្រម Wang Tieya ចៅក្រម Rafael Nieto-Navia និង ចៅក្រម Florence Ndepele Mwachande Mumba ។ មេធាវីការពារក្តីនឹងមានក្តីតក់ស្លុតបើសិនជាចៅក្រមជាទីគោរពនៃអង្គបុរេជំនុំជម្រះ និងជាពិសេសអ្នកសម្របសម្រួលកិច្ចការតុលាការជាន់ខ្ពស់នៃអង្គបុរេជំនុំជម្រះ មិនបានដឹងនូវការពិតនៅពេលដែលចេញនូវសេចក្តីអញ្ជើញដោយសំអាងលើបទពិសោធន៍របស់ពួកគេ ។ ដូច្នេះ វាត្រូវគេបានសន្មតថា សេចក្តីអញ្ជើញត្រូវធ្វើឡើងដោយអាចដឹងបានយ៉ាងពេញលេញនូវតួនាទីរបស់សាស្ត្រាចារ្យ **កាសេស៊ី** (Cassese) ក្នុងការបង្កើត សហកម្មឧក្រិដ្ឋកម្មរួម និង សេចក្តីប្រកាសជាបន្តបន្ទាប់របស់គាត់ទៅលើបញ្ហានេះ។

29. នៅក្នុងអត្ថបទថ្មីៗស្តីពីប្រធានបទនេះ ដែលសរសេរដោយ សាស្ត្រាចារ្យ **កាសេស៊ី** (Cassese) ក្នុងឋានៈជា "សមាជិកម្នាក់នៃគណៈកម្មាធិការនិពន្ធនាយក[52]" គាត់បានអះអាងថា ទម្រង់ទាំងបីនៃសហកម្មឧក្រិដ្ឋកម្មរួម ឥឡូវ"ត្រូវបានព្រមទទួលយកយ៉ាងទូលំទូលាយ" ដោយតុលាការនិងអង្គជំនុំជម្រះអន្តរជាតិ ហើយថា វាគឺជាទ្រឹស្តីមួយ "ត្រូវគេបានកំណត់អត្ថន័យយ៉ាងច្បាស់លាស់"[53]។ ម្យ៉ាងទៀត គាត់បានបដិសេធចោលទាំងស្រុងនូវទឡ្ហីករណ៍ដែលថា សហកម្មឧក្រិដ្ឋកម្មរួម មិនត្រូវបានបង្កើតឡើង ស្របទៅតាមការវិភាគត្រឹមត្រូវលើច្បាប់ទំនៀមទំលាប់អន្តរជាតិ និងដែលថាវាជាឧទាហរណ៍មួយរបស់តុលាការដែលប្រើប្រាស់នូវឆន្ទានុសិទ្ធហួសហេតុ។ គាត់ធ្វើនេះដោយគ្មានតម្រូវការអោយមានការពិភាក្សាដោយយោងទៅច្បាប់ទំនៀមទំលាប់ ដោយថ្លែងថា៖ "អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់យ៉ាងត្រឹមត្រូវថា ពាក្យថា "ការប្រព្រឹត្ត" មានអត្ថន័យជាទូទៅមួយ ដែលអាចត្រូវកំណត់អត្ថសញ្ញាណដោយស្របច្បាប់ដោយឈរលើមូលដ្ឋាននៃច្បាប់ទំនៀមទំលាប់អន្តរជាតិ"[54]។

30. វាមិនអាចទៅរួចទេសំរាប់សាស្ត្រាចារ្យ **កាសេស៊ី** (Cassese) ក្នុងការដោះស្រាយបញ្ហាដែលកំណត់ដោយអង្គបុរេជំនុំជម្រះ ដោយមានគំនិតទូលំទូលាយ និងដោយមិនលំអៀង។ ភស្តុតាងបង្ហាញ *ហួសពីភាពថែមឡូ* ថាគោលជំហររបស់គាត់អំពី សហកម្មឧក្រិដ្ឋកម្មរួម គឺមិនអាចផ្លាស់ប្តូរបាន។

### 3. សាស្ត្រាចារ្យ កាសេស៊ី (Cassese) មិនមានលទ្ធភាពដើម្បីកំណត់បង្ហាញអោយបានច្បាស់ចង្អុលចរិកលក្ខណៈ និង ពិនិត្យពិច័យដោយមានភាពមិនលំអៀងលើសេចក្តីសន្និដ្ឋានអោយមានជម្រើសផ្សេងស្តីពីការអនុវត្តនូវការទទួលខុសត្រូវជាទម្រង់ សហកម្មឧក្រិដ្ឋកម្មរួម ឡើយ

31. ដោយហេតុថាការពឹងផ្អែកដែលចេះតែកើនឡើងទំលាក់លើសារណានៃ *អ្នកដែលមិនមែនជាភាគី*ដោយតុលាការ និងអង្គជំនុំជម្រះ ទាក់ទងនឹងបញ្ហានៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ វាជាការសំខាន់

[52] អត្ថបទរបស់ **កាសេស៊ី** ទំព័រ ១០៩

[53] *ដូចយោងខាងលើ* ទំព័រ ១១០

[54] *ដូចយោងខាងលើ* ទំព័រ ១១៤

ដែលសារណាទាំងនោះបំរើអោយផលប្រយោជន៍យុត្តិធម៌ ហើយមិនត្រូវប្រើប្រាស់ដើម្បីបំរើផលប្រយោជន៍ទាំងរបស់ *អ្នកដែលមិនមែនជាភាគី* ឬ ទាំងរបស់គូភាគីនោះទេ[55]។

32. ដើម្បីបំរើអោយផលប្រយោជន៍យុត្តិធម៌លើបញ្ហានេះ សាស្ត្រាចារ្យ **កាសេស៊ី** (Cassese) ត្រូវតែមានលទ្ធភាពដើម្បីកំណត់បង្ហាញអោយបានច្បាស់ ចង្អុលចរិកលក្ខណៈ និង ពិនិត្យពិច្ច័យទៅលើបណ្តាទឡ្ហីករណ៍របស់អ្នកទាំងនោះដែលប្រកាន់ទស្សនៈផ្សេងពីគាត់ ។ អត្ថបទស្រាវជ្រាវជាន់ខ្ពស់របស់គាត់បង្ហាញការមិនមានលទ្ធភាពយ៉ាងច្បាស់លាស់ដើម្បីធ្វើដូច្នេះបាន ។ នៅក្នុងអត្ថបទថ្មីៗដែលប៉ុនប៉ងៗជំទាស់នឹងទឡ្ហីករណ៍ជាច្រើនដែលប្រឆាំងនឹង សហកម្មឧក្រិដ្ឋកម្មរួម គាត់បានច្រានចោលយ៉ាងពេញទំហឹងស្ទើរតែទាំងអស់នូវការតិះទៀនទាំងឡាយប្រឆាំងនឹងវា[56] ។ ចម្លើយតបតែមួយគត់ទៅនឹងទឡ្ហីករណ៍ដែលថា ការប្រព្រឹត្តរួមគ្នាគឺទម្រង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌមួយដែលត្រឹមត្រូវជាងសហកម្មឧក្រិដ្ឋកម្មរួម ហើយថាការពិតប្រហែលជាមានការគាំទ្រខ្លះៗនៅក្នុងច្បាប់ទំនៀមទំលាប់អន្តរជាតិ គឺថា "*វាគឺជាអង្គហេតុដែលអង្គជំនុំជម្រះតុលាការកំពូល* ICTY *បានបដិសេធចោល*" [57]។ ការច្រានចោលលើកក្រោមមកទៀតរបស់គាត់ចំពោះការជំទាស់ដែលថាអង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្តី **តាឌិច** ក្នុងបង្កើតសហកម្មឧក្រិដ្ឋកម្មរួម "ពឹងផ្អែកលើទស្សនាទាននៃប្រព័ន្ធច្បាប់**ខុមម៉ុនឡ** (common law) ខណៈដែលប្រើប្រាស់ក្នុងពេលជាមួយគ្នានូវពាក្យតាមបែបប្រពៃណីនៃច្បាប់**ស៊ីវិលឡ** (civil law)" គឺថា ទោះបីជា "នេះគឺជាពិតដែលគ្មានមន្ទិល [...] លក្ខណៈគ្រឹះនៃទ្រឹស្តីនេះគឺរឹងមាំណាស់ ហើយការប្រើប្រាស់នូវភាសាដែលនាំអោយភ័ន្តច្រលំបន្តិចបន្តួច មិនធ្វើអោយខាតបង់តម្លៃនៃភាពត្រឹមត្រូវជាមូលដ្ឋាននៃទស្សនាទាននេះឡើយ" [58]។ សាស្ត្រាចារ្យ **កាសេស៊ី** (Cassese) មិនផ្តល់នូវមូលដ្ឋានជាសំអាងដែលអាចយល់បាន តាមផ្លូវច្បាប់ ឬ ផ្សេងពីនេះ សំរាប់ចម្លើយតបតែមួយបន្ទាត់ទៅនឹងទឡ្ហីករណ៍ជាគោលសំខាន់ ។ បើសិន សាស្ត្រាចារ្យ **កាសេស៊ី** (Cassese) ត្រូវបានអនុញ្ញាតអោយដាក់សារណាជាលាយលក្ខណ៍អក្សរទៅលើបញ្ហាដែលកំណត់ដោយ អង្គបុរេជំនុំជម្រះនោះគ្មានអ្វីគួរអោយឆ្ងល់ទេ វានឹងមានបញ្ចូលនូវអំណះអំណាងដែលបដិសេធប្រហែលគ្នានេះ ។

---

[55] សូមមើល រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង* Norman, សេចក្តីសំរេចស្តីពីពាក្យសុំជាបឋមផ្អែកលើកង្វះយុត្តាធិការ (ការជ្រើសរើសកុមារ) ចុះថ្ងៃទី ៣១ ឧសភា ២០០៤ SCSL-2004-14-AR72(E) UNICEF ។

[56] *សូមមើល* អត្ថបទរបស់ **កាសេស៊ី** ។

[57] អត្ថបទរបស់ **កាសេស៊ី** ទំព័រ ១១៥ ។

[58] *ដូចយោងខាងលើ*

B. **ចៅក្រម**

1. **សាស្ត្រាចារ្យ កាសេស៊ី (Cassese) និងសមាជិកមួយចំនួនត្រូវបានស្នើសុំអោយធ្វើសកម្មភាពក្នុងឋានៈជាចៅក្រម**

33. អង្គបុរេជំនុំជម្រះបានអញ្ជើញសាស្ត្រាចារ្យ **កាសេស៊ី** (Cassese) និងគណៈកម្មាធិការនិពន្ធនាយកអោយសារណាជាលាយលក្ខណ៍អក្សរ ទៅលើបញ្ហាពីរទាក់ទងនឹងឋានៈនៃសហកម្មឧក្រិដ្ឋកម្មរួមនៅក្នុងច្បាប់ទំនៀមទំលាប់អន្តរជាតិ និងថាតើ វាអាចនឹងត្រូវគេអនុវត្តនៅ អ.វ.ត.ក ចំពោះឧក្រិដ្ឋកម្មដែលចោទថាបានប្រព្រឹត្ត ក្នុងរវាងឆ្នាំ ១៩៧៥ ដល់ ១៩៧៩ ដែរឬទេ។ ដោយស្នើសុំអោយមានសារណាជាលាយលក្ខណ៍អក្សរអំពីបញ្ហាសំខាន់ និងស្មុគស្មាញទាំងនេះ អង្គបុរេជំនុំជម្រះទំនងជាបានទុកជាមោឃៈនូវករណីកិច្ចដ៏ចម្បងរបស់ខ្លួន ដើម្បីសំរេចដោយខ្លួនឯងទៅលើបញ្ហាសំខាន់ជាសារវន្តថាតើ អ.វ.ត.ក អាចអនុវត្ត សហកម្មឧក្រិដ្ឋកម្មរួម ថាជាទម្រង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌចំពោះឧក្រិដ្ឋកម្មដែលស្ថិតក្នុងវង្វង់យុត្តាធិការរបស់ខ្លួននោះ ។ ផ្ទុយទៅវិញ អង្គបុរេជំនុំជម្រះបានប្រគល់អោយអ្នកខាងក្រៅនូវដំណោះស្រាយដោយតុលាការលើបញ្ហានេះ ដោយផ្ទាល់សំដៅសាស្ត្រាចារ្យ **កាសេស៊ី** (Cassese) ។

34. ខណៈដែលវាជាញឹកញាប់មានការលំបាកដើម្បីកំណត់ថា អ្វីជាបញ្ហាសំខាន់ជាសារវន្តនៃករណីវិវាទគឺជាជំនួយ អាចផ្តល់ដោយយុត្តិសាស្ត្រដ៏រឹងមាំទៅលើអ្វីដែលបង្កើតបានជាបញ្ហាដែលប្តឹងឧទ្ធរណ៍បាននៅក្នុងបណ្តឹងឧទ្ធរណ៍ដោយឆន្ទានុសិទ្ធិ ។ ដើម្បីការអនុញ្ញាតប្តឹងឧទ្ធរណ៍អាចផ្តល់ជូន ភាគីស្វែងរកការប្តឹងឧទ្ធរណ៍ត្រូវកំណត់បង្ហាញនូវបញ្ហាដែល "បង្កើតបានជាប្រធានបទ ដែលដំណោះស្រាយទៅលើបញ្ហានោះមានសារៈសំខាន់ សំរាប់ការកំណត់បញ្ហាដែលកើតឡើងទៅជាមូលហេតុតាមផ្លូវតុលាការស្ថិតនៅក្រោមការពិនិត្យពិច័យ" [59]។ និយាយដោយងាយ បញ្ហាមួយនឹងអាចត្រូវបានប្តឹងឧទ្ធរណ៍បានលុះត្រាតែវានឹងត្រូវបានសំរេចដោយចៅក្រម ឬ អង្គជំនុំជម្រះ ដើម្បីចេញសេចក្តីសំរេចចុងក្រោយមួយទៅលើបញ្ហាដែលនៅក្នុងដៃ ។ ការសំរេចលើបញ្ហាចម្បងទាំងនេះគឺជាមុខងារដ៏ខ្ពង់ខ្ពស់របស់ចៅក្រម។

---

[59] *ស្ថានភាពនៅសាធារណៈរដ្ឋប្រជាធិបតេយ្យកុងហ្គោ* ICC-01/04 សាលដីកាសំរេចលើពាក្យសុំអោយមានការពិនិត្យឡើងវិញជាវិសាមញ្ញលើសេចក្តីសំរេចថ្ងៃទី ៣១ មីនា ២០០៦ របស់អង្គបុរេជំនុំជម្រះទី ១ បដិសេធការទុកអោយប្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ១៣ កក្កដា ២០០៦ កថាខណ្ឌ ៩ ។

35. នៅក្នុងករណីបច្ចុប្បន្ននេះ ដំណោះស្រាយលើប្រធានបទដែលកំណត់នៅក្នុងសេចក្តីអញ្ជើញ គឺមានសារៈសំខាន់ដើម្បីកំណត់ថាតើ សហកម្មឧក្រិដ្ឋកម្មរួម អាចនឹងត្រូវអនុវត្តនៅ អ.វ.ត.ក ដែរឬក៏អត់។ ដោយផ្តល់អោយមុខងារតុលាការនេះទៅដល់ សាស្ត្រាចារ្យ **កាសេស៊ី** (Cassese) និង គណៈកម្មាធិការនិពន្ធនាយកមួយចំនួន និងដោយស្នើអោយពួកគេដោះស្រាយបញ្ហាទាំងនេះនៅទីកន្លែងរបស់ខ្លួន អង្គបុរេជំនុំជម្រះបានបង្ហាញអោយអ្នកទាំងនោះនូវកាតព្វកិច្ចដូចគ្នាដូចនឹងចៅក្រមនៃ អ.វ.ត.ក ដទៃទៀតដែរ។

36. ជាចៅក្រមនៃ អ.វ.ត.ក សាស្ត្រាចារ្យ **កាសេស៊ី** (Cassese) និង គណៈកម្មាធិការនិពន្ធនាយក ត្រូវតែប្រតិបត្តិតាមកាតព្វកិច្ចដែលដាក់មកលើចៅក្រមតាមក្រមសីលធម៌ចៅក្រមនៃ អ.វ.ត.ក, តាមវិធានផ្ទៃក្នុង ៣៤ និង តាមយុត្តិសាស្ត្រដែលទាក់ទងនឹងអនាគតិដែលបានដាក់ចេញរួចមកហើយដោយអង្គបុរេជំនុំជម្រះ ក៏ដូចជាតុលាការចំពោះកិច្ចដទៃទៀតដែរ ។

### 2. សាស្ត្រាចារ្យ កាសេស៊ី (Cassese) និង គណៈកម្មាធិការនិពន្ធនាយកគឺមិនឯករាជ្យ និង មានភាពលំអៀង

37. មេធាវីការពារក្តីបានពន្យល់យ៉ាងពិស្តារខាងលើរួចមកហើយ ថាហេតុអ្វីសាស្ត្រាចារ្យ **កាសេស៊ី** (Cassese) និង គណៈកម្មាធិការនិពន្ធនាយក មានភាពលំអៀងទៅលើបញ្ហា សហកម្មឧក្រិដ្ឋកម្មរួម [60]។ គោលជំហរមិនប្រែប្រួលរបស់សាស្ត្រាចារ្យ **កាសេស៊ី** (Cassese) លើបញ្ហានេះ ការមិនមានលទ្ធភាពរបស់ខ្លួនដើម្បីចង្អុលចរិកលក្ខណៈ និង ពិនិត្យពិច្ច័យអោយបានត្រឹមត្រូវ ហើយដោះស្រាយលើទស្សនៈសុពលអោយបានស្មើភាពគ្នានៃអ្នកទាំងនោះ ដែលគោលជំហររបស់ពួកគេគឺខុសប្លែកពីគោលជំហររបស់គាត់ ហើយផលប្រយោជន៍របស់គាត់ក្នុងការលើកតម្កើងនូវគំនិតដែលថា សហកម្មឧក្រិដ្ឋកម្មរួម បានអភិវឌ្ឍន៍ទៅជាបទដ្ឋានទំនៀមទំលាប់ដោយសារតែវាត្រូវបានប្រើប្រាស់ដោយតុលាការដទៃទៀត នៅមុនរឿងក្តី **តាឌិច** បង្ហាញនូវអវត្តមានទាំងស្រុងនូវអនាគតិទៅបញ្ហានេះ។ សូម្បីតែ អង្គបុរេជំនុំជម្រះ សន្និដ្ឋានថា អនាគតិគឺមិនចាំបាច់សំរាប់ *អ្នកដែលមិនមែនជាភាគី* ដោយគ្មានមន្ទិល វាជាកាតព្វកិច្ចតាមក្រមសីលធម៌ចាំបាច់សំរាប់ចៅក្រម ។ បើសិនសាស្ត្រាចារ្យ **កាសេស៊ី** (Cassese) និង គណៈកម្មាធិការនិពន្ធនាយក ព្រមទទួលតាក់តែងនូវ សារណាជាលាយលក្ខណ៍អក្សរ

---

[60] *យោងពីខាងមុខ* កថាខណ្ឌ ២១ ដល់ ៣០ ។

នេះ ពួកគេនឹងរំលោពបំពាននូវកាតព្វកិច្ចនេះ ហេតុដូច្នេះ ត្រូវតែបាត់បង់គុណវុឌ្ឍិសំរាប់ធ្វើការងារនេះ ។

3. **សាស្ត្រាចារ្យ កាសេស៊ី (Cassese) នឹងដើរតួយ៉ាងមានប្រសិទ្ធិភាពជាចៅក្រមលើបណ្តឹងឧទ្ធរណ៍លើសេចក្តីសំរេចរបស់ខ្លួន**

38. សាស្ត្រាចារ្យ **កាសេស៊ី** (Cassese) ដោយដើរតួជា *អ្នកដែលមិនមែនជាភាគី* លើបញ្ហាទាក់ទងនឹងសហកម្មឧក្រិដ្ឋកម្មរួម គឺស្រដៀងគ្នានឹងចៅក្រមជំនុំជម្រះដែលជម្រះលើបណ្តឹងឧទ្ធរណ៍ផងដែរ។ នឹងធ្វើអោយកើតមាននូវជម្លោះផលប្រយោជន៍យ៉ាងច្បាស់ក្រឡែត ដែលគួរតែត្រូវដកគាត់ចេញជាស្វ័យប្រវត្តិពីការដើរតួជា *អ្នកដែលមិនមែនជាភាគី* ។ សាស្ត្រាចារ្យ **កាសេស៊ី** (Cassese) នឹងរំលោភបំពានបញ្ញត្តិជាមូលដ្ឋាន ដែលថា "គ្មានចៅក្រមណាត្រូវជម្រះលើបណ្តឹងឧទ្ធរណ៍ទៅលើរឿងក្តីដែលចៅក្រមនោះ ធ្លាប់ជាសមាជិកអង្គជំនុំតុលាការដំបូង" [61] ខណៈដែលគាត់នឹងជំនុំជំរះដើម្បីពិនិត្យឡើងវិញនូវសាលដីកានៅក្នុង រឿងក្តី **តាឌិច** ដោយរំលោភបំពានយ៉ាងច្បាស់ក្រឡែតនូវវិធាន ។

**C ដំណោះស្រាយ**

39. មានប្រភេទផ្សេងៗគ្នានៃដំណោះស្រាយដែលអាចរកបាន ដែលអង្គបុរេជំនុំជម្រះអាចបង្កាប់ទាក់ទងទៅនឹងកង្វះអនាគតិដែលបង្ហាញឡើងចំពោះ សាស្ត្រាចារ្យ **កាសេស៊ី** (Cassese) និង គណៈកម្មាធិការនិពន្ធនាយក ។

2. **ការដកយកមកវិញនូវសេចក្តីអញ្ជើញ**

40. ដំណោះស្រាយដែលប្រកបដោយប្រសិទ្ធិភាពបំផុត និងដោយសំចៃដល់តុលាការគឺ អោយ អង្គបុរេជំនុំជម្រះគ្រាន់តែដកយកមកវិញនូវសេចក្តីអញ្ជើញរបស់ខ្លួន ទៅសាស្ត្រាចារ្យ **កាសេស៊ី** (Cassese) និង គណៈកម្មាធិការនិពន្ធនាយក ។ ការណ៍នេះនឹងធានាបានថា ទាំងសាស្ត្រាចារ្យ **កាសេស៊ី** (Cassese) និង គណៈកម្មាធិការនិពន្ធនាយក នឹងមិនចំណាយពេល និងកិច្ចខិតខំប្រឹងប្រែងធ្វើការស្រាវជ្រាវដ៏ស្មុគស្មាញ និងដោយការពុះពារ ដែលវានឹងតម្រូវអោយត្រៀមរៀបចំនូវ សារណាជាលាយ

---

[61] *សូមមើល* វិធាន ១៥ (ឃ) (២) នៃ វិធាននៃនីតិវិធី និងភស្តុតាងនៃតុលាការសំរាប់អតីតយូហ្គោស្លាវី ICTY

លក្ខណ៍អក្សរតាមសំណើសុំ។ ការដកហូតមកវិញនេះនឹងធានាថា អង្គបុរេជំនុំជម្រះ នឹងមិនបង្ហាញអោយគេឃើញនូវសារណាដែលជិតដាមទៅដោយអនាគតិ។

### 2. ការមិនបញ្ចូលនូវសារណាជាលាយលក្ខណ៍អក្សរដែលដាក់ជូន សាស្ត្រាចារ្យ កាសេស៊ី (Cassese) និង គណៈកម្មាធិការនិពន្ធនាយក

41. ប្រសិនបើ សាស្ត្រាចារ្យ **កាសេស៊ី** (Cassese) និង គណៈកម្មាធិការនិពន្ធនាយក ដាក់សារណាជាលាយលក្ខណ៍អក្សរ នៅមុនពេលមានសេចក្តីសំរេចរបស់អង្គបុរេជំនុំជម្រះ ដកយកមកវិញនូវសេចក្តីអញ្ជើញរបស់ខ្លួន សារណានោះត្រូវតែបដិសេធចោល។ លទ្ធភាពបែបនេះគឺបើកទូលាយដល់ អង្គបុរេជំនុំជម្រះ ទាក់ទងនឹងសេចក្តីពន្យល់ និងអំណះអំណាងទាំងឡាយដែលរៀបរាប់នៅក្នុងសារណានេះ។ វាស្ថិតនៅក្នុងរង្វង់អំណាចរបស់ អង្គបុរេជំនុំជម្រះ ដើម្បីធ្វើបែបនេះ ថ្វីបើការពិតដែលថា អង្គបុរេជំនុំជម្រះ ជាអ្នកដែលបានចេញនូវសេចក្តីអញ្ជើញនេះតាំងពីដំបូងដែរក៏ដោយ[62]។

### 3. ការដាក់ជូននូវសារណាជាលាយលក្ខណ៍អក្សរដោយសមាជិកនៃអ្នកនិពន្ធទាំងឡាយដែលមានភាពមិនលំអៀង ស្តីពីការអនុវត្តនូវការទទួលខុសត្រូវជាទម្រង់សហកម្មឧក្រិដ្ឋកម្មរួម

42. មេធាវីការពារក្តីបានធ្វើសេចក្តីបញ្ជាក់នៅក្នុងឧបសម្ព័ន្ធយ៉ាងពិស្តារមួយ ជាមួយនឹងពាក្យស្នើសុំនេះ នូវអ្នកសមាជិកទាំងឡាយនៃក្រុមប្រឹក្សានិពន្ធ និងគណៈកម្មាធិការនិពន្ធនៃទិនានុប្បវត្តិ សំរាប់ហេតុដូចគ្នានឹងសាស្ត្រាចារ្យ **កាសេស៊ី** (Cassese) ដែលគួរត្រូវបានហាមឃាត់មិនអោយធ្វើជា*អ្នកដែលមិនមែនជាភាគី* [63]។ នៅមានសល់សមាជិកនៃក្រុមប្រឹក្សានិពន្ធ និងគណៈកម្មាធិការនិពន្ធមួយចំនួនទៀតនៃទិនានុប្បវត្តិ ដែលនឹងមិន "អាចនាំអោយមានការកត់សម្គាល់មួយដ៏សមហេតុផលមួយ និងមានព័ត៌មានត្រឹមត្រូវចំពោះការយល់ដឹងអំពីការលំអៀងដោយសមហេតុផល[64]" ផ្អែកទៅលើព័ត៌មានដែលស្ថិតនៅក្នុងដៃរបស់មេធាវីការពារក្តី។ ហេតុដូច្នេះហើយ នៅដំណាក់កាលនេះ មេធាវីការពារក្តីនៅតែរក្សា

---

[62] ព័ត៌មានសំរាបតុលាការសំរាប់អតីតយូហ្គោស្លាវី ICTY កថាខណ្ឌ ៥(គ)

[63] *សូមមើល* ឧបសម្ព័ន្ធ ក ។

[64] សាលដីកាតុលាការកំពូលក្នុងរឿងក្តី *Furundžija* កថាខណ្ឌ ១៨៩ ។

ការមិនជំទាស់តវ៉ាទៅនឹង សមាជិកនៃក្រុមប្រឹក្សានិពន្ធ និងគណៈ-កម្មាធិការនិពន្ធ ទាំងឡាយដែលមិនប្រឡាក់ប្រឡូស អោយដាក់សារណាជាលាយលក្ខណ៍អក្សរឆ្លើយតបទៅនឹងសេចក្តីអញ្ជើញនោះ។

43. ប្រសិនបើ សាស្ត្រាចារ្យ **កាសេស៊ី** (Cassese) ត្រូវបាត់បង់គុណវុឌ្ឍិពីការចូលរួមនៅក្នុងការត្រៀមរៀបចំតាក់តែងនូវសារណាជាលាយលក្ខណ៍អក្សរនេះ វានឹងមានលំអានដោយសមហេតុសមផលដែលថា គាត់នឹងមិនត្រូវអនុញ្ញាតអោយជ្រើសរើសនូវសមាជិកនិពន្ធដែលនៅសេសសល់ទាំងឡាយដែលនឹងមកជំនួសកន្លែងគាត់ ។ ថ្វីបើ វិធានផ្ទៃក្នុងនៃ អ.វ.ត.ក មិនចែងនូវនីតិវិធីដែលនឹងត្រូវយកលំនាំតាមនៅពេលដែលមានការជំនួសចៅក្រមដែលអស់គុណវុឌ្ឍិ សេចក្តីណែនាំអាចស្វែងបានពីវិធាននៃតុលាការសំរាប់អតីតយូហ្គោស្លាវី ICTY ដែលនឹងដោះស្រាយដោយផ្ទាល់នូវបញ្ហានេះ។ វិធាន ១៥(ក) អនុញ្ញាតអោយមានការដកហូតចៅក្រមប្រសិនបើមានបញ្ហាដែលប៉ះពាល់ដល់អនាគតិរបស់ចៅក្រម។ នៅក្នុងករណីបែបនេះ ប្រធានតុលាការត្រូវតែងតាំងអ្នកជំនួស។ វិធាន ១៥(ខ)(៤) ចែងថា បើសិនប្រធានតុលាការគឺជាអ្នកដែលមានបញ្ហាទាក់ទងអនាគតិ ចៅក្រមដែលមានតំណែងជាន់ខ្ពស់បន្ទាន់ពីនេះ នឹងត្រូវកាន់កាប់នូវតំណែងនេះតាមវិធាន ១៥ ។ ហេតុដូច្នេះ បើសិនប្រធានតុលាការត្រូវគេចោទប្រកាន់ថាលំអៀង គាត់មិនអាចតែងតាំងអ្នកជំនួសបានឡើយ។ ន័យស្រដៀងគ្នានេះ វាមានលំអានថា សាស្ត្រាចារ្យ **កាសេស៊ី** (Cassese) ត្រូវបានហាមឃាត់មិនអោយតែងតាំងអ្នកជំនួសដើម្បីត្រៀមរៀបចំនូវ សារណាជាលាយលក្ខណ៍អក្សរតាមសំណើសុំដោយអង្គបុរេជំនុំជម្រះ ប្រសិនបើគាត់ត្រូវអស់គុណវិឌ្ឍិ។ ដោយស្មើភាពគ្នា រាល់សមាជិកនិពន្ធដទៃទៀតដែលត្រូវអស់គុណវុឌ្ឍិ ត្រូវហាមឃាត់ដូចគ្នាមិនអោយជ្រើសរើសអ្នកជំនួស។

### 4. សំណើអោយមានជំរើសផ្សេងចំពោះ *អ្នកដែលមិនមែនជាភាគី*

44. ប្រសិនបើ អង្គបុរេជំនុំជម្រះ អនុញ្ញាតអោយ សាស្ត្រាចារ្យ **កាសេស៊ី** (Cassese) និងសមាជិកដទៃខ្លះទៀតនៃទិនានុប្បវត្តិ នូវឱកាសដើម្បីបង្ហាញអោយឃើញនូវការប្រឹងខាងផ្លូវច្បាប់របស់ពួកគេ និងធ្វើសកម្មភាពដោយវិធីផ្សេងទៀតដែលជាចាំបាច់ការពារ និងបន្ថែមនូវផលប្រយោជន៍របស់ ការិយាល័យសហព្រះរាជអាជ្ញា ដោយព្យាយាមធ្វើអោយ សហកម្មឧក្រិដ្ឋកម្មរួម រឹងមាំជានិរន្តន៍នៅក្នុងយុត្តិសាស្ត្រអន្តរជាតិ ដូច្នេះហើយគេត្រូវអញ្ជើញគូវិវាទដែលមានសមភាពនៃមធ្យោបាយការពារតតាំងនឹងភូតហេតុសហកម្មឧក្រិដ្ឋកម្មរួម ដើម្បីធ្វើជា *អ្នកដែលមិនមែនជាភាគី* ដោយចង្អុល

បង្ហាញនូវគុណវិប្បត្តិ និងជំនឿរខុស ដែលនឹងបន្សល់ទុកដោយមិនមានការតតាំងដោយក្រុមរបស់សាស្ត្រាចារ្យ **កាសេស៊ី** (Cassese) ដែលមានភាពលំអៀងទាំងស្រុង។

45. ការពង្រីកនូវសេចក្តីអញ្ជើញបន្ថែមទៅអោយ សមាគម ADC-ICTY អោយដាក់សារណាជាលាយលក្ខណ៍អក្សរគឺមានភាពសមរម្យ។ សមាគម ADC-ICTY នឹងចាត់ចែងនាំមកជាមួយនូវមតិយោបល់ជាសមូហភាព និងទស្សនវិស័យរបស់ក្រុមមេធាវីការពារក្តីនៅ តុលាការសំរាប់អតីតយូហ្គោស្លាវី ICTY ។ សមាគម ADC-ICTY ពីមុនត្រូវបានអញ្ជើញអោយ តុលាការសំរាប់អតីតយូហ្គោស្លាវី ICTY អោយដាក់សារណាជាលាយលក្ខណ៍អក្សរ និងធ្វើសេចក្តីសន្និដ្ឋានដោយផ្ទាល់មាត់នៅក្នុងដំណើរការបណ្តឹងឧទ្ធរណ៍ស្តីពី សហកម្មឧក្រិដ្ឋកម្មរួម[65] ។ មេធាវីការពារក្តីបានគូសចំណាំថា លោក **ម៉ៃឃើល ខាណាវ៉ាស** សហមេធាវីបរទេសរបស់**លោក អៀង សារី** បច្ចុប្បន្ននេះជាប្រធាននៃ សមាគម ADC-ICTY នេះ។ តាមធម្មតា ដោយរក្សាទុកនូវទឡ្ហីករណ៍ពីមុននៅទីនេះ ជំទាស់នឹង សាស្ត្រាចារ្យ **កាសេស៊ី** (Cassese) និង សមាជិកនិពន្ធមួយចំនួនដែលនឹងត្រូវសមនឹងធ្វើជា *អ្នកដែលមិនមែនជាភាគី* បើសិនជា សមាគម ADC-ICTY នឹងត្រូវអញ្ជើញអោយធ្វើសារណាជាលាយលក្ខណ៍អក្សរ លោក **ខាណាវ៉ាស** នឹងមិនត្រឹមតែតម្រូវអោយដកខ្លួនឯងចេញប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងនឹងដកខ្លួនចេញពីការជ្រើសរើសនូវសមាជិកនៃ សមាគម ADC-ICTY ដែលនឹងចូលរួមនៅក្នុងការតាក់តែងនូវសារណានេះ ។

46. ជាជម្រើស មានអ្នកឯកទេសច្បាប់អន្តរជាតិដទៃទៀត ដែលនឹងផ្តល់នូវការវិភាគឥតលំអៀងជាងសាស្ត្រាចារ្យ **កាសេស៊ី** (Cassese) ។ ខណៈដែលបញ្ហាលើកឡើងដោយ អង្គបុរេជំនុំជម្រះ ទាក់ទងជាក់លាក់ទៅនឹងឋានៈនៃ សហកម្មឧក្រិដ្ឋកម្មរួម នៅក្នុងច្បាប់ទំនៀមទំលាប់អន្តរជាតិ និងបញ្ហាទាក់ទងទៅនឹងថាតើច្បាប់ទំនៀមទំលាប់អន្តរជាតិ អាចនឹងត្រូវបានអនុវត្តនៅ អ.វ.ត.ក ដែរឬទេនោះ អ្នកឯកទេសនៅក្នុងការអនុវត្តច្បាប់អន្តរជាតិម្នាក់គឺនឹងគ្រប់គ្រាន់ជាជាងអ្នកឯកទេសតាមការសន្មតម្នាក់នៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ។ អ្នកឯកទេសបែបនេះ នឹងមិនដែលចោទប្រកាន់

---

[65] *រដ្ឋអាជ្ញា តតាំងនឹង Brđanin*, សំណុំរឿងលេខ IT-99-36-A, សេចក្តីសំរេចស្តីពីញត្តិស្នើសុំបដិសេធចោលនូវទឡ្ហីករណ៍ទីមួយនៃបណ្តឹងឧទ្ធរណ៍របស់រដ្ឋអាជ្ញា ចុះថ្ងៃទី ៥ ឧសភា ២០០៥ ។ សូមមើល *រដ្ឋអាជ្ញា តតាំងនឹង v. Brđanin, សំណុំរឿង* IT-99-36-A, សេចក្តីសំរេចលើសំណើរបស់សមាគមមេធាវីការពារក្តី ADC សុំចូលរួមក្នុងការទាញហេតុផលដោយផ្ទាល់មាត់ ចុះថ្ងៃទី ៧ វិច្ឆិកា ២០០៥ ។ *សូមមើលផងដែរ* សេចក្តីសន្និដ្ឋានផ្ទាល់មាត់របស់សមាគមមេធាវីការពារក្តី ADC នៅក្នុងរឿងក្តី *រដ្ឋអាជ្ញា តតាំងនឹង Brđanin សំណុំរឿង* IT-99-36-A ប្រតិចារឹកនៃនីតិវិធីបណ្តឹងឧទ្ធរណ៍ ទំព័រ ៦៤-៧២ ចុះថ្ងៃទី ៧ ធ្នូ ២០០៦។

ការពារក្ដី ឬ កាត់សេចក្ដីនៅក្នុងការជំនុំជម្រះក្ដីព្រហ្មទណ្ឌដែលទាក់ទងនឹងអនុវត្តនូវ សហកម្មឧក្រិដ្ឋកម្មរួម។ វាគ្រាន់តែស្ថិតនៅឆ្ងាយបន្ដិចពីប្រធានបទដែល *អ្នកដែលមិនមែនជាភាគី* នឹងមានលទ្ធភាពអនុវត្តនូវការពិចារណាដែលមិនទាក់ទង ដូចជាគោលនយោបាយសាធារណៈ ឬសារជាតិតាមការសន្មត នៃឧក្រិដ្ឋកម្មអន្តរជាតិពីឥទ្ធិពលនៃដំណោះស្រាយរបស់អ្នកនោះលើបញ្ហានេះ។

## V. សេចក្ដីសន្និដ្ឋាន និង ការស្វែងរកឧបាស្រ័យ

47. មេធាវីការពារក្ដីត្រូវបានតក់ស្លុតជាខ្លាំង តាមរយៈសេចក្ដីអញ្ជើញសាស្ត្រាចារ្យ **កាសេស៊ី** (Cassese) ដែលបានចេញដោយ អង្គបុរេជំនុំជម្រះ ។ វាទំនងជាគ្មានអ្វីច្រើនជាងការប៉ុនប៉ងដោយលាក់មុខបន្ដិចបន្តួចដើម្បីជួលបន្តនូវមុខងារតុលាការដ៏ត្រឹមត្រូវរបស់ អង្គបុរេជំនុំជម្រះ ទៅ សាស្ត្រាចារ្យ **កាសេស៊ី** (Cassese) ជាមួយគ្នាសមាជិកនិពន្ធមួយចំនួន។ សាស្ត្រាចារ្យ **កាសេស៊ី** (Cassese) និងក្រុមរបស់គាត់គឺគ្រាន់តែកញ្ចោងផ្សេងដែលឃាមកាមរោងចិញ្ចឹមមាន់របស់ សហកម្មឧក្រិដ្ឋកម្មរួម ប៉ុណ្ណោះ មិនមែនគ្រាន់តែចៃដន្យទេ កេរ្ដិ៍ដំណែលនៅក្នុងសន្ទានុក្រមច្បាប់អន្តរជាតិ។ គ្មានផលិតផលខាងបញ្ញាថ្មី និងការវិភាគថ្មីៗ នឹងចេញមកពីការសិក្សាដែលអ្នកតស៊ូមតិនៃសហកម្មឧក្រិដ្ឋកម្មកសាងយ៉ាងរឹងមាំ រួចមកហើយ ។ វានឹងមានភាពងាយស្រួលច្រើនជាងនេះ ដោយកោះអញ្ជើញក្រុមមជ្ឈធាតុនិយម និង អ្នកតិទៀន អោយជ្រៀតជ្រែកទៅក្នុងក្របខណ្ឌនៃ សហកម្មឧក្រិដ្ឋកម្មរួម និង ជួយបិតភ្ជិតនូវចន្លោះប្រហោង និងជួយក្នុងការកំណត់ថាតើ សហកម្មឧក្រិដ្ឋកម្មរួម គឺជាទម្រង់រឹងមាំ ដោយកសាងលើមូលដ្ឋានដែលមាំទាំ ឬ ក៏ប្រៀបដូចជាផ្ទះដែលធ្វើពីបំពង់បឺតទឹកដែលមិនរឹងមាំ ដែរឬទេ ។ នៅទីបញ្ចប់ ប្រសិនបើ អង្គបុរេជំនុំជម្រះ ពិតជាពឹងផ្អែកទៅលើ *អ្នកដែលមិនមែនជាភាគី* ដែលលំអៀងបែបនោះមែន ដោយមិនថ្លឹងថ្លែង ឬ មានចំណុចប្រឆាំងទេ ដូច្នេះវានឹងលះបង់នូវអនាគតិរបស់ខ្លួន [66]។

---

[66] តាមពិត ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្ស បានអំពាវនាវជាញឹកញាប់អោយកម្ពុជាបង្កើនកិច្ចប្រឹងប្រែងដើម្បីអភិវឌ្ឍនូវប្រព័ន្ធយុត្តិធម៌មួយដែលមានអនាគត និងឯករាជ្យ ។ *សូមមើល* ដំណោះស្រាយរបស់មហាសន្និបាត លេខ ៥៥/៩៥ (A/Res/55/95) ចុះថ្ងៃទី ២៨ មករា ២០០១ ។ កំណត់ហេតុស្ដីពីកំណែទម្រង់ច្បាប់ និងតុលាការនៃកិច្ចប្រជុំពិគ្រោះយោបល់នៃប្រទេសអ្នកផ្ដល់ជំនួយពាក់កណ្ដាលឆមាស ខែ មករា ២០០៣ ។ សេចក្ដីប្រកាសព័ត៌មាន៖ *តំណាងពិសេសនៃអគ្គលេខាធិការ អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា និង អ្នករាយការណ៍ពិសេសទទួលបន្ទុកឯករាជ្យភាពនៃចៅក្រម និង មេធាវី សំដែងក្ដីកង្វល់អំពីឯករាជ្យភាពនៃតុលាការនៅប្រទេសកម្ពុជា ដែលទាក់ទងនឹងការតែងតាំងចៅក្រមនាពេលថ្មីៗនេះ*

**អាស្រ័យហេតុនេះ** សម្រាប់ហេតុផលទាំងអស់ដែលបានលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍នេះ មេធាវីការពារ សូមសំណូមពរដោយក្តីគោរពដល់អង្គបុរេជំនុំជម្រះសូម៖

i. **ដកហូតមកវិញ** នូវសេចក្តីអញ្ជើញ *អ្នកដែលមិនមែនជាភាគី* ដែលចង្អុលទៅកាន់ សាស្ត្រាចារ្យ **កាសេស៊ី** (Cassese) និង សមាជិកដទៃទៀតនៃក្រុមប្រឹក្សានិពន្ធ និងគណៈកម្មាធិការនិពន្ធ នៃ *ទិនានុប្បវត្តិនៃតុលាការយុត្តិធម៌អន្តរជាតិ*

ii. **បដិសេធចោល** នូវសារណាជាលាយលក្ខណ៍អក្សរដែលដាក់ជូនដោយ សាស្ត្រាចារ្យ **កាសេស៊ី** (Cassese) និង សមាជិកដទៃទៀតនៃក្រុមប្រឹក្សានិពន្ធ និងគណៈកម្មាធិការនិពន្ធនៃ *ទិនានុប្បវត្តិនៃតុលាការយុត្តិធម៌អន្តរជាតិ* ដែលមានភាពលំអៀងទៅលើការអនុវត្តនូវសហកម្មឧក្រិដ្ឋកម្មរួម

iii. **ហាមឃាត់** សាស្ត្រាចារ្យ **កាសេស៊ី** (Cassese) និង សមាជិកនិពន្ធមួយចំនួនមិនអោយជ្រើសរើស សមាជិកនៃក្រុមប្រឹក្សានិពន្ធ និងគណៈកម្មាធិការនិពន្ធនៃ *ទិនានុប្បវត្តិនៃតុលាការយុត្តិធម៌អន្តរជាតិ* ដែលមិនមានកង្វះខាតនូវអនាគតិ ដើម្បីតាក់តែងនូវសារណាតាមការស្នើសុំដោយ អង្គបុរេជំនុំជម្រះ ឬ

iv. **អញ្ជើញ** សមាគមមេធាវីការពារក្តីប្រកបវិជ្ជាជីវៈនៅតុលាការ ICTY អោយដាក់សារណាជាលាយលក្ខណ៍អក្សរទាក់ទងនឹងបញ្ហាទាំងពីរ ដែលលើកឡើងនៅក្នុងសេចក្តីអញ្ជើញ *អ្នកដែលមិនមែនជាភាគី* របស់ អង្គបុរេជំនុំជម្រះ ដែលចេញនៅថ្ងៃទី ២៣ កញ្ញា ២០០៨ ក្នុងរយៈពេលមួយខែ បន្ទាប់ពីចេញសេចក្តីសំរេចតាមសំណើសុំនេះ។

---

សេចក្តីថ្លែងការណ៍រួមរបស់លោក **យ៉ាស ហ្គាយ** (Yash Ghai) តំណាងពិសេសនៃអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា និង **លានដ្រូ ដេសពួយ** (Leandro Despouy) អ្នករាយការណ៍ពិសេសទទួលបន្ទុកឯករាជ្យភាពនៃចៅក្រម និងមេធាវីចុះថ្ងៃទី ២៣ សីហា ២០០៧ ។

00225633

០០១/១៨-០៧-២០០៧-អវតក-កសចស(អបជ០២)

D99/3/18

សូមអង្គបុរេជំនុំជម្រះទទួលយកសំណើសុំនេះដោយក្តីគោរព។

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី ៣ ខែតុលា ឆ្នាំ ២០០៨

ព្រះរាជាណាចក្រកម្ពុជា មេធាវី AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

អាង ឧត្តម Michael G. KARNAVAS

សហមេធាវីរបស់លោក អៀង សារី